**PTI0078**

# សម្ភាសន៍ជាមួយឈ្មោះ ព្រាប កប ភេទប្រុស អាយុ៦១ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម«យោធា»

ស្រុកកំណើតនៅភូមិចានទាប ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ

រស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០១:២២:១៤

៣៧ទំព័រ

វណ្ណៈ: ចឹងថ្ងៃហ្នឹងថ្ងៃទី២២ខែ៥ឆ្នាំ២០១១ ។

កបៈ បាទ ។

វណ្ណៈ: ហើយខ្ញុំឈ្មោះ សុខ វណ្ណៈ ។

កបៈ បាទ ។

វណ្ណៈ: ខ្ញុំមកពីខាងអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា មកដល់ភូមិឃុំពូចង់ដឹងពីប្រវត្តិដែលទាក់ទងនិងសម័យឆ្លងកាត់កន្លងមកហើយចង់ដឹងពីការវិវត្តន៍ឥឡូវ តើជីវភាពប្រជាជនយើងមានជីវភាពយ៉ាងម៉េច ហើយពូមុនមកធ្លាប់ជួបការលំបាកអ្វីខ្លះ?

កបៈ បាទ ។

វណ្ណៈ: ចឹងបទសម្ភាសខ្ញុំជាមួយពូ តើពូអាចឲ្យខ្ញុំយកទៅប្រើការដូចជាយកទៅសរសេរជាសៀវភៅទុកជាប្រវត្តិសាស្រ្តបានទេ?

កបៈ ចុះមានអី អត់បញ្ហាទេ ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូដែរ ពូឈ្មោះអីទៅ?

កបៈ ខ្ញុំឈ្មោះ ព្រាប កប ។

វណ្ណៈ: ចឹងពូអាយុប៉ុន្មានហើយពូ?

កបៈ ខ្ញុំអាយុ៥៦ ។

វណ្ណៈ: ប្រពន្ធពូឈ្មោះអីដែរ?

កបៈ ឈ្មោះ ណុប នឹម ។

វណ្ណៈ: អាយុប៉ុន្មានដែរ?


66 Preah Sihanouk Blvd. ♦ P.O.Box 1110 ♦ Phnom Penh ♦ Cambodia
t (855-23) 211-875 ♦ f (855-23) 210-358 ♦ dccam@online.com.kh ♦ www.dccam.org

កបៈ	អាយុគាត់៦០ហើយ ខ្ញុំបើនិយាយឲ្យត្រង់ទៅខ្ញុំអាយុ៦១ហើយ តែនេះខ្ញុំនិយាយអាយុខ្ញុំក្នុងការងារទេ ។

វណ្ណៈ	ចឹងនិយាយអាយុក្នុងការងារ?

កបៈ	បាទ ។

វណ្ណៈ	ចឹងអាយុពិត៦១?

កបៈ	៦១យកអាយុពិតទៅ ។

វណ្ណៈ	ចឹងពូមានកូនចៅប៉ុន្មាន?

កបៈ	ខ្ញុំកូនពីរ ។

វណ្ណៈ	ចឹងមានកូនតែពីរនាក់?

កបៈ	បាទ ។

វណ្ណៈ	ចឹងសព្វថ្ងៃកូនពីរហ្នឹងធំៗអស់ហើយ?

កបៈ	រៀបការអស់ហើយ ។

វណ្ណៈ	ចឹងនៅតែពីរនាក់តា យាយទេ?

កបៈ	បាទ ។

វណ្ណៈ	ហើយស្រុកកំណើតពូនៅភូមិអី?

កបៈ	នៅភូមិចានទាប ។

វណ្ណៈ	ឃុំ?

កបៈ	ឃុំសំរោង ។

វណ្ណៈ	ស្រុក?

កបៈ	ស្រុកត្រាំកក់ ។

វណ្ណៈ	ខេត្ត?

កបៈ	ខេត្តតាកែវ ។

វណ្ណៈ	ឥឡូវពូនៅភូមិអីឥឡូវ?

កបៈ	នៅភូមិដីក្រហម ឃុំអន្លង់រាប ។

វណ្ណៈ	ស្រុកវាលវែង?

កបៈ	បាទ ។

វណ្ណៈ	ចឹងខេត្តពោធិ៍សាត់ពូ?

កបៈ	បាទ ។

វណ្ណៈ៖ ចឹងឪពុកពូឈ្មោះអីដែរ?

កបៈ ឪពុកខ្ញុំឈ្មោះ ព្រាប អាង ។

វណ្ណៈ៖ ម្ដាយ?

កបៈ អ៊ូ ហ៊ុន ។

វណ្ណៈ៖ ចឹងសព្វថ្ងៃគាត់ស្លាប់ឬមួយយ៉ាងម៉េច?

កបៈ ស្លាប់យូរហើយ ។

វណ្ណៈ៖ ស្លាប់ជំនាន់ណា?

កបៈ ស្លាប់យើងក្រោយ៧៩នេះ ។

វណ្ណៈ៖ ចឹងពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

កបៈ មានបួននាក់ ។

វណ្ណៈ៖ ចឹងមានតែបួននាក់ហ្នឹងសព្វថ្ងៃមកនៅហ្នឹងដែលឬយ៉ាងម៉េច?

កបៈ អត់ទេ នៅស្រុកកំណើតនោះ ។

វណ្ណៈ៖ ចឹងកាលពីតូចពូរៀនបានដល់ថ្នាក់ណា?

កបៈ កាលសម័យសង្គមរាស្ត្រនិយមខ្ញុំរៀននៅសាលាស៊ីសុវត្ថ ។

វណ្ណៈ៖ ចឹងរៀននៅវិទ្យាល័យស៊ីសុវត្ថ?

កបៈ បាទ ។

វណ្ណៈ៖ ចឹងរៀននៅវិទ្យាល័យស៊ីសុវត្ថហ្នឹងរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរ?

កបៈ ខ្ញុំពីដើមរៀនបានថ្នាក់ទី៨ ។

វណ្ណៈ៖ រៀនបានថ្នាក់ទី៨បានច្រើន ទី៨ចាស់?

កបៈ បាទ ។

វណ្ណៈ៖ ចឹងកាលនៅភូមិពូរៀននៅសាលាណាដែរ?

កបៈ រៀននៅភូមិខ្ញុំរៀននៅសាលាបឋមសិក្សាដ្ទឹកជ្រុំហ្នឹងតែម្ដង ។

វណ្ណៈ៖ ចឹងពូរៀននៅសាលាស៊ីសុវត្ថហ្នឹងពូរៀននៅណា ហើយពូឈប់រៀននៅពេលណាដែរ?

កបៈ ខ្ញុំឈប់នៅថ្ងៃរដ្ឋប្រហារ ។

វណ្ណៈ៖ ចឹងដោយសារសង្គ្រាមឆ្នាំ៧០ហ្នឹង?

កបៈ បាទ! ថ្ងៃទី១៨ហ្នឹង ថ្ងៃរដ្ឋប្រហារហ្នឹង ។

វណ្ណៈ៖ ចឹងរដ្ឋប្រហារថ្ងៃ១៨មិនា?

កបៈ បាទ! ឆ្នាំ៧០ ។

វណ្ណៈ ចឹងក្រោយពីពូឈប់រៀនហើយពូបន្តទៅធ្វើអីទៀតទៅពូ?

កប៖ ក្រោយពីឈប់រៀនហ្នឹងខ្ញុំត្រឡប់មកផ្ទះវិញ ប្រទេសមានសង្គ្រាមហើយឪពុកម្ដាយគាត់ឈប់ឲ្យរៀនខ្ញុំត្រឡប់មកស្រុកកំណើតវិញក្នុងឆ្នាំ៧០ហ្នឹងដែរ បែបហែលជាខែ១០ខ្ញុំចេញមកតស៊ូហើយ ។

វណ្ណៈ ចឹងពូយល់យ៉ាងម៉េចដែលបានពូចេញមកតស៊ូនៅក្នុងពេលហ្នឹង?

កប៖ កាលជំនាន់នោះខ្ញុំបានស្ដាប់វិទ្យុ ខ្ញុំបើកវិទ្យុរណសិរ្សរួបរួមជាតិដែលមានសម្ដេចតាសព្វថ្ងៃព្រះអង្គជាប្រធាននោះណាស់ គាត់អំពាវនាវឲ្យយុវជនយុវតីហ្នឹងចូលព្រៃម៉ាគីចូលតស៊ូរួមរួបជាតិកាលហ្នឹងគេថាវៃពួកយៀកកុងនោះណាស់ ។ ខ្ញុំក៏ចូលទៅបានប្រមូលយុវជនទៅជាមួយគ្នាហ្នឹងប្រហែលជា៦០ទៅ៧០នាក់ ចូលតស៊ូទៅធ្វើកងទ័ព ជំនាន់ហ្នឹងគេហៅកងទ័ពបដិវត្តន៍នោះ ។

វណ្ណៈ ចឹងស្ដាប់តាមការប្រកាសរបស់សម្ដេចឪ?

កប៖ បាទ!ហើយមានខ្លះនៅតាមផ្នែកមូលដ្ឋានមានការឃោសនាដែរ មិនមែនទៅអត់មានខ្សែក្រឡួសទេ មាននៅតាមភូមិឃុំគេមានខ្សែគេដើរអប់រំផ្សព្វផ្សាយគេមានប្រមូលកំលាំងយុវជនយុវនារីធ្វើកងទ័ពបដិវត្តន៍ហ្នឹង ។

វណ្ណៈ ចឹងកាលពូប្រមូលចូលហ្នឹងមានគ្នា៦០នាក់ដែរ?

កប៖ បាទ ។

វណ្ណៈ ចូលនៅណាដំបូង?

កប៖ ខ្ញុំចូលនៅស្រុកកំណើតតែម្ដង ។

វណ្ណៈ ចូលនៅស្រុកកំណើតហ្នឹងពេលហ្នឹងយើងចេញទៅព្រៃហើយមែនទេ?

កប៖ បាទ ។

វណ្ណៈ ចឹងចេញទៅព្រៃយើងបង្កើតចលនាតស៊ូប្រឆាំងជាមួយទាហានលន់ នល់អីហ្នឹង?

កប៖ បាទ ។

វណ្ណៈ ចឹងកាលពីឆ្នាំ៧០ទៅមានទម្លាក់គ្រាប់បែកហើយនៅពូ"បេ៥២អី"?

កប៖ យើងអត់មានទាន់ទម្លាក់ទេ "បេ៥២អី" បេ៥២ដែលវាទម្លាក់២០០យប់២០០ថ្ងៃហ្នឹងឆ្នាំ៧៣ ។

វណ្ណៈ ចឹងឆ្នាំ៧៣?

កប៖ បាទ!ទម្លាក់ខ្លាំងតែម្ដងហ្នឹង ។

វណ្ណៈ ទម្លាក់គ្រាប់បែកបេ៥២ហ្នឹង មានគ្រោះថ្នាក់យ៉ាងណាខ្លះដែរ?

កបៈ	បើនិយាយពីគ្រោះថ្នាក់ខ្ទិចខ្ទីរភូមិកនោះ ខ្ញុំឃើញជាក់ស្តែងដូចជា នៅម្តុំខាងលិចបែកគូសហ្នឹង គេហៅភូមិព្រៃជីរភូមិអីហ្នឹងណាស់ ខាងជើងអន្លុរណាហ្នឹងខ្ទិចទាំងភូមិហើយ នៅខាងស្រុកខ្ញុំហ្នឹង ខ្ទិចទាំងភូមិដែរ ។

វណ្ណៈ	បាទ ។

កបៈ	ចាក់មកមួយខ្សែៗវាគឺអស់ទាំងភូមិតែម្តង ។

វណ្ណៈ	ចឹងប្រជាជនមានស្លាប់?

កបៈ	ស្លាប់នោះមិនបាច់និយាយទេ ។

វណ្ណៈ	ចឹងនៅពេលមានបេ៥២ទម្លាក់ចឹងទៅ តើប្រជាជនហ្នឹងគាត់រត់ចូលព្រៃថែមឬរត់មកខាងលន់ នល់?

កបៈ	អត់ទេ គាត់នៅក្នុងភូមិកាលហ្នឹងដែលជិនាន់ហ្នឹងបេ៥២ដែលវាទម្លាក់កំទេចកំលាំងរបស់ខ្មែរ ក្រហម ។

វណ្ណៈ	បាទ ។

កបៈ	ប៉ុន្តែវាមិនត្រូវខ្មែរក្រហម ព្រោះកងទ័ពខ្មែរក្រហមនៅជាប់បន្ទាយនោះហ្នឹង ឧទាហរណ៍ភូមិ យើងទាំងមូលមានទីតាំងរបស់ទាហានចឹង ហើយបេ៥២វាផ្ញើសកម្មភាពចឹងកងទ័ពនៅជាប់ របងបន្ទាយ ។

វណ្ណៈ	បាទ ។

កបៈ	ដល់វាខាងក្រោយមានត្រូវកងទ័ពណា មានត្រូវទាហានខ្មែរក្រហមអីត្រូវតែប្រជាជនក្នុងភូមិ វាវៃមួយភូមិៗខ្ទិច ពិសេសនៅខាងលិចថ្នល់វិហារខ្ពស់យើងតាកែវហ្នឹង ខ្ញុំនៅហ្នឹងហើយ ។

វណ្ណៈ	បាទ ។

កបៈ	ខ្ទិចគ្មានសល់ទេ ភូមិមួយៗ ។

វណ្ណៈ	ចឹងមានត្រូវវត្តអីខ្លះទេ?

កបៈ	ត្រូវចឹងហើយបានខ្ញុំស្តាប់វិទ្យុវីអូអេគេចងប្រវត្តិសាស្ត្រខ្ញុំថា អ្នកចងហ្នឹងចេះតែនិយាយ ហើយនិយាយមិនពិតទេ ។

វណ្ណៈ	បាទ ។

កបៈ	ហើយតាមរយៈលោកហ្នឹងសុំណុំពរផង កុំចេះតែស្រែកបើចងៗឲ្យទាំងអស់កុំចងមួយលែង មួយ ។

វណ្ណៈ	បាទ ។

កបៈ	អាមេរិចកាំងក៏ចង យួនក៏ចងយួនសម្លាប់ខ្មែរផ្លូវនេះ ខ្មែរស្លាប់រាប់ម៉ឺននាក់ដោយសារពលករ

កំណែន«ក៥» បើចង់ៗឲ្យអស់កុំចង់មួយលែងមួយ ។

វណ្ណៈ បាទ ។

កបៈ យើងធ្វើជាអ្នកប្រវត្តិសាស្រ្តចឹងបំបាត់ឲ្យអស់សរសេរឲ្យអស់ ចេះៗឲ្យចប់បើចេះឲ្យគេកោង បើឆោតឲ្យគេអាណិតខ្ញុំសូមណូមពរចឹងទេ ។

វណ្ណៈ បាទ ។

កបៈ ខ្ញុំធុញដែលតើ ធុញរឿងអ្នកចង់ប្រវត្តិសាស្រ្តហ្នឹង ស៊ីកញ្ជាស៊ី សេង ធារី សេង ធារីហ្នឹង ណាស់ ស្មើតាមហ្នឹងទៅប្រាប់ដង បើចង់ៗឲ្យសព្វកុំបំបាត់រឿង ធ្វើឲ្យក្មេងជំនាន់ក្រោយវា បាត់សត្តិបាត់ប្រវត្តិកំកែប្រវត្តិសាស្រ្ត អាមេរិចកាំង់ក៏សម្លាប់ខ្មែរ ទោះបីធ្វើអាមេរិចកាំងមិន បានក៏ដោយគេជាមហាអំណាចគេជាមហាសេដ្ឋីមែនទេ ។

វណ្ណៈ បាទ ។

កបៈ តែប្រវត្តិសាស្រ្តត្រូវចង់ឲ្យមាន យើងធ្វើអីយួនមិនកើតក៏ដោយតែត្រូវចង់ប្រវត្តិសាស្រ្តឲ្យវា មាន យួនសម្លាប់ខ្មែរតាមឈាមត្រជាក់ ។

វណ្ណៈ ចឹងយើងជាអ្នកប្រវត្តិសាស្រ្តត្រូវដឹងទាំងអស់?

កបៈ ត្រូវដឹងទាំងអស់ ។

វណ្ណៈ ចឹងអ៊ីដែលពូបានដឹងពូនិយាយមក ព្រោះពូជាជនរងគ្រោះ?

កបៈ បាទ ។

វណ្ណៈ យើងជាជនរងគ្រោះយើងត្រូវហ៊ានបញ្ចេញមតិថា ឥឡូវហេតុការណ៍អ្នកនយោបាយពីមុន ដើងចាស់មកដឹកនាំមកហ្នឹងវាមានលក្ខណៈចេះមួយៗ ហើយខ្មែរបានលាបពណ៌វៃគ្នាដោយ សារវាចេះៗ ចឹងបើសិនជាពូជាជនរងគ្រោះចឹងបើសិនជាពូប្រាប់មកខានខ្ញុំអាចយកទៅសរ សេរជាប្រវត្តិសាស្រ្តថារឿងហ្នឹង វាមិនមែនខុសតែម្នាក់ៗទេ?

កបៈ បាទ ។

វណ្ណៈ ចឹងវាមានខុសពីរបីចំណែកទាំងអស់គ្នា ចឹងត្រូវឲ្យដឹងទាំងអស់គ្នាពូណែស?

កបៈ បាទ! ហើយគាត់ថាយើងមិនអាចធ្វើអីគេបានទេ ព្រោះគេមហាអំណាចគេអ្នកមាន ចឹងសេង ធារីហ្នឹងមិនត្រឹមត្រូវទេ អាមេរិចកាំងមានក៏ដោយអ្នកឯងសម្លាប់ខ្មែរត្រូវតែនិយាយ ។

វណ្ណៈ បាទ ។

កបៈ យួនហ្នឹងក៏ដោយយើងធ្វើអីយួនមិនកើតក៏ត្រូវតែនិយាយចងជាប្រវត្តិទុកឲ្យក្មេងជំនាន់ក្រោយ វាដឹង ខ្មែរក្រហមកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរថា ជារបបប្រល័យពូជសាសន៍ក៏យើងត្រូវតែ សរសេរដែរ ដើម្បីទុកឲ្យក្មេងជំនាន់ក្រោយវាដឹង ។

វណ្ណៈ បាទ ។

កបៈ ពីទសវត្សរ៍មួយទៅទសវត្សរ៍ តើខ្មែររងគ្រោះដោយសារអ្នកណាខ្លះចឹងទេ ។

វណ្ណៈ បាទ ។

កបៈ ឲ្យវាចប់ត្រឹមត្រូវមក ចឹងខ្ញុំស្តាប់ការសម្ភាសរបស់មី សេង ធារីហ្នឹងវានៅក្មេងណាស់ វាជនភាសខ្លួនរត់ទៅនៅអាមេរិចទេ វាកើតជំនាន់ក្រោយទេ ឯខ្ញុំនេះប្រាប់អូនឯងឲ្យត្រង់ទៅពូឆ្លងកាត់សព្វគ្រប់ពី៧០រហូតមកដល់សមាហរណ៍កម្មខ្ញុំនៅខ្លួនឯងហ្នឹងផ្ទាល់ដឹងសភាពការណ៍ទាំងអស់ ។

វណ្ណៈ បាទ ។

កបៈ អ្នកណាធ្វើយ៉ាងម៉េចអ្នកណាធ្វើយ៉ាងម៉េច ហើយសម័យប៉ុល ពតហ្នឹងខ្ញុំក៏ជាមនុស្សរងគ្រោះមួយដែរ ។

វណ្ណៈ បាទ ។

កបៈ សូម្បីតែខ្ញុំពិការហើយប៉ុណ្ណឹងក៏គេប្រើដែរ ហើយសម័យនោះដោយសារខ្ញុំនៅរស់ដោយសារខ្ញុំលាក់ខ្លួនទេ លាក់យ៉ាងម៉េចខ្ញុំនៅគាខ្មៅខ្ញុំឃើញនិសិត្សមកនៅគាខ្មៅហ្នឹងហើយគេសម្លាប់នៅគាខ្មៅហ្នឹង ខ្ញុំនៅគាខ្មៅនៅមជ្ឈមណ្ឌលពិការ ខ្ញុំនៅវត្តព្រែកបុស្សី ។

វណ្ណៈ បាទ ។

កបៈ ព្រែកបុស្សីព្រែកឡុងយើងព្រែករាំងនេះ កំពង់សំណាញ់នេះសុទ្ធតែជាកន្លែងខ្ញុំនៅហើយ ។

វណ្ណៈ បាទ!ចឹងមានន័យថាពូពិការ តាំងពីពូមិនទាន់ចូលដល់ភ្នំពេញម្លេះ?

កបៈ ខ្ញុំពិការឆ្នាំ៧៥ ។

វណ្ណៈ ចឹង៧៥ពេលចូលភ្នំពេញហ្នឹងតែម្តង?

កបៈ បាទ ។

វណ្ណៈ ចឹងពូ៧០រហូត៧៥ពូមានតួនាទីខ្លះនៅកាលជំនាន់ហ្នឹង?

កបៈ បាទ!មានហើយ ។

វណ្ណៈ កាលហ្នឹងពូមានឋានៈអីដែរ?

កបៈ ឋានៈជាប្រធានវរៈសេនាតូច ។

វណ្ណៈ ចឹងដល់ពូពិការទៅពូដែលកាន់អីទៀតហើយ?

កបៈ បាទ!ដល់យើងពិការទៅ យើងលែងមានតួនាទីកាន់កងទ័ពទៀតហើយយើងនៅតែកន្លែងពិការហ្នឹងទេ ព្រោះយើងពិការហើយ ។

វណ្ណៈ បាទ ។

កបៈ គេឲ្យនៅមន្ទីរពិការ ។

វណ្ណៈ ចឹងកាលឆ្នាំ៧០-៧១-៧២-៧៣ហ្នឹងមក ពីណាជាប្រធានកងពលកាលហ្នឹង?

កបៈ ប្រធានកងពលជំនាន់ខ្ញុំហ្នឹងគាត់ស្លាប់អស់ហើយ ។

វណ្ណៈ ពីណាគេ?

កបៈ មានបង ឌុល បង ផល តែខ្ញុំអត់មានចាំនាមត្រកូលគាត់ទេណាស់ ។

វណ្ណៈ បាទ ។

កបៈ មានតា វ៉ែនអីហ្នឹងគាត់ស្លាប់អស់ហើយ ។

វណ្ណៈ តាវ៉ែន?

កបៈ បាទ!ស្លាប់អស់ហើយ តា សឿនរថក្រោះអីនេះហ្នឹងសុទ្ធតែមេៗខាងលើៗខ្ញុំហើយណាស់ គេហៅតា សឿនរថក្រោះ តាវ៉ែន ឌុល តា ផល តា ឈៀងណាស់ ។

វណ្ណៈ បាទ ។

កបៈ គាត់ស្លាប់អស់ហើយ ។

វណ្ណៈ ចឹងកាលហ្នឹងពូនៅភូមិភាគណា?

កបៈ ខ្ញុំនៅភូមិភាគនិរតី ។

វណ្ណៈ ចឹងតំបន់?

កបៈ តំបន់១៣ ។

វណ្ណៈ ចឹងតំបន់១៣?

កបៈ បាទ!តាកែវ យើងហ្នឹងគេឲ្យតំបន់១៣ជំនាន់ហ្នឹង ។

វណ្ណៈ ចឹងនាពេលវ៉ៃចូលភ្នំពេញ ពូមានបានវ៉ៃចូលដល់ភ្នំពេញទេ?

កបៈ បាន ។

វណ្ណៈ ចឹងមកដល់ភ្នំពេញដែរ?

កបៈ បាទ ។

វណ្ណៈ ចឹងពូមកដល់ភ្នំពេញហ្នឹងពូពិការហើយនៅ?

កបៈ ខ្ញុំភ្នំពេញខ្ញុំអត់បានចប់ចុងចប់ដើមទេ ខ្ញុំត្រូវពិការថ្ងៃទី១២មេសា ។

វណ្ណៈ ចឹងមុន៥ថ្ងៃ?

កបៈ បាទ!មុនចូលដល់ភ្នំពេញ៥ថ្ងៃ ខ្ញុំត្រូវរបួសថ្ងៃទី១២មេសាហ្នឹងតែម្តង ។

វណ្ណៈ ចឹងថ្ងៃទី១២មេសាឆ្នាំ៧៥?

កបៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងកុំតែពូត្រូវបួសព្រោះពូរៀនបានច្រើនដែរចឹងត្រូវមានឋានៈបន្តបន្ទាប់ទៀត?

កបៈ បាទ ។

វណ្ណៈ ចឹងនៅពេលត្រូវបួសចឹងទៅគេ?

កបៈ យើងដាច់ពីចលនាកងទ័ព ។

វណ្ណៈ ចឹងដាច់ពីកងទ័ពនៅមន្ទីរពិការ?

កបៈ បាទ! នៅមន្ទីរពិការ ។

វណ្ណៈ ចឹងកំលាំងចលនាចូលព្រៃខ្មែរក្រហម ចឹងកាលហ្នឹងមានទ័ពវៀតណាមខាងជើងជួយដែរ កាលក៏កើតដំបូង?

កបៈ កកើតដំបូងយើងនៅចំរុះជាមួយពួកវៀតណាមខាងជើង គេហៅថាពួកហាន់ណូយ ។

វណ្ណៈ បាទ! ហើយខាងលន់មានខាងធៀវគី?

កបៈ ហ្នឹងហើយធៀវគីហើយខ្ញុំហ្នឹងវ៉ៃទប់ទល់ជាមួយពួកធៀវគីនៅភ្នំដិន ។

វណ្ណៈ បាទ ។

កបៈ នៅភ្នំដិន នៅពោធិរោង ពោធិសន្ដែអីហ្នឹង ក្រោយឃ្លោកយើងខាងកោះអណ្ដែតនេះ ។

វណ្ណៈ បាទ ។

កបៈ ពួកខ្ញុំចុះទៅវ៉ៃខាងហ្នឹងហើយទប់ទល់ជាមួយពួកធៀវគី ។

វណ្ណៈ ចឹងនៅពេលវ៉ៃជាមួយពួកធៀវគីពួកលន់ នល់ហ្នឹង តើពីមានឃើញសកម្មភាពពីការរងគ្រោះស្លាប់ហ្នឹងមានដូចគ្នាឬមួយយ៉ាងម៉េចដែរ វ៉ៃគ្នាកាលហ្នឹង?

កបៈ វាជារឿងធម្មតាទេ សង្គ្រាមបាចទឹកដាក់គ្នាវាតែងតែទទឹកទាំងសងខាងហើយ ។

វណ្ណៈ ចឹងនៅខាងចលនាតស៊ូក្នុងព្រៃហ្នឹង តើអាវុធអីនិងគ្រឿងសម្ភារអីមានខាងណាជួយដែរ?

កបៈ កាលហ្នឹងខ្ញុំមិនសូវដឹងរឿងដែរ ឃើញយើងទៅធ្វើទ័ពចឹងទៅ យើងរៀបចំកងទ័ពខ្វះអាវុធឃើញគេបញ្ជូនអាវុធទៅឲ្យគេដឹកទៅឲ្យ កាលហ្នឹងមិនមានឡានទេ ។

វណ្ណៈ បាទ ។

កបៈ យើងប្រើរទេះគោរទេះក្របីដឹកជញ្ជូន តែអាវុធហ្នឹងបានពីប្រភពណាខ្ញុំក៏មិនសូវដឹងដែរ តែអាវុធជំនាន់ខ្ញុំហ្នឹងវាមិនបានទំនើបដូចជាឥឡូវទេ យើងប្រើតែពួក«មូស្គុង អង់ខ្សែល តាំសុនការ៉ាប៊ីនអីហ្នឹង» ។

វណ្ណៈ បាទ ។

កបៈ ហើយមាន«សេកាសេ ការងលម្អងហ្នឹង» ប្រើពួកអាហ្នឹង ។

វណ្ណៈ ចឹងបើមានម៉ាកអ៊ីមម៉ាសីទាល់តែវ៉ៃបានពីខាងទាហានលន់ នល់?

កបៈ	បាទ!ដល់ក្រោយមកទៀតយើងបានរបស់ជ័យភ័ណ្ឌយើងវ៉ៃឈ្នះទាហានចិនទៅ  យើងបានអាវុធល្អៗបំពាក់ឲ្យកងទ័ពដែលដូចជាអ៊ីមម៉ាសីដែលយើងហៅថាអាអែ១៥ៗអាអែ១៦ហ្នឹង ។

វណ្ណៈ	បាទ ។

កបៈ	យើងបានបំពាក់ឲ្យកងទ័ពបានល្អៗដែលក្រោយមក  តែចូលដំបូងអត់មានអីទេ  មានតែពួកកាំភ្លើងចាស់ៗ ។

វណ្ណៈ	ចឹងកាលចូលចលនាដំបូងអត់មានពីណាមកបង្ខំទេ មានទឹកចិត្តសោះត្រង់?

កបៈ	អត់មានទេ  អត់មានទេជំនាន់ខ្ញុំចូលតស៊ូនិងគឺព្រោះខ្ញុំមនុស្សគេហៅថា  បើក្នុងគំនិតទៅយើងជាប់ខត្តមគតិពីជំនាន់សង្គមរាស្ត្រនិយមមក  ជាប់លិទ្ធិពីសង្គមរាស្ត្រនិយមមកយើងមានទឹកចិត្តស្រឡាញ់សម្ដេចឪហ្នឹង សម្ដេចតាហ្នឹង ។

វណ្ណៈ	បាទ ។

កបៈ	ចឹងស្មគ្រចូលធ្វើកងទ័ពបណ្ដោយដើម្បីវ៉ៃផ្តួលរំលំរបបលន់  នល់ហ្នឹងយករាជ្យបល្ល័ង្កថ្វាយព្រះអង្គវិញ ។

វណ្ណៈ	បាទ ។

កបៈ	តែដល់ក្រោយមកគេក្រឡៃទៀតទៅ  ដូចថាមាន់គេគៀងចូលក្នុងទ្រុងយើងទៅស្លុះណារួចមិនចឹង ។

វណ្ណៈ	បាទ!ចឹងកាលសម័យពួតស៊ូហ្នឹង  ពូមានឮឈ្មោះមេដឹកនាំកំពូលៗខ្លះហើយនៅដូចជា  ហ៊ូ  នឹម ហ៊ូ  យន់  ខៀវ  សំផន  ប៉ុល  ពតអីចឹង  កាលសម័យតស៊ូហ្នឹងមានឮហើយនៅ?

កបៈ	កាលខ្ញុំចូលចលនាតស៊ូដំបូងអត់មានឮឈ្មោះទេ តាៗអស់ហ្នឹង ។

វណ្ណៈ	ចឹងឮតែសម្ដេចឪមួយទេកាលហ្នឹង?

កបៈ	បាទ!គាត់ស្រែកតាមវិទ្យុរណសិរ្សរួមរួបជាតិហ្នឹងណាស់  ហើយនិងតាអៀង  សារីហ្នឹង ។

វណ្ណៈ	បាទ!ចឹងគាត់មានចុះមកផ្ទាល់រៀបទ័ពអីទេ?

កបៈ	អត់ទេ ។

វណ្ណៈ	ចឹងបើគាត់ចុះមកមានចុះមកខាងសៀមរាបចឹង?

កបៈ	បាទ!ខ្ញុំឮតែឈ្មោះ  ប៉ុន្មាននាក់ទេកាលជំនាន់ហ្នឹងខ្ញុំឮតែឈ្មោះ  តា  ហ៊ូ  យន់  តា  ហ៊ូ  នឹម ខៀវ  សំផននិងអៀង  សារីហើយសម្ដេចឪហ្នឹង  មានប៉ុន្មាននាក់ហ្នឹងទេ  ដែលខ្ញុំបានដឹងនោះណាស់ ។

វណ្ណៈ	ចឹងឆ្នាំណាដែលបានឮឈ្មោះគាត់?

កបៈ	ឮឆ្នាំ៧០និង៧១ហ្នឹងឮឈ្មោះគាត់មានវិទ្យុរណសិរ្សរួបរួមជាតិ  យើងបើវិទ្យុណាស់ស្ងួណាល់

ប្រើអាពីរបង់បីបង់អីនោះបានយើងចាប់បានអាហ្នឹង បើវិទ្យុមួយបង់យើងប្រើចាប់សម្លេងហ្នឹងបានទេ ។

វណ្ណៈ: បាទ ។

កបៈ: ដឹងគេបញ្ជូនផ្សាយចេញពីណា យើងប្រើវិទ្យុអាមួយបង់យើងអត់ចាប់បានទេ ទាល់តែចាប់ពីរបង់ឡើងទៅ ។ យើងសេរ៉េរកតាមលលកធាតុអាកាសតាមគេផ្សាយយើងចាំម៉ោងយើងបើកទៅព្រហើយគេមានកម្មវិធីនយោបាយគេផ្សព្វផ្សាយតាមវិទ្យុហ្នឹង ។

វណ្ណៈ: បាទ!ចឹងជិនាន់បីឆ្នាំហ្នឹងដែលពូនៅតាខ្មៅហ្នឹងដែលពូនៅកន្លែងមន្ទីរពិការចឹង?

កបៈ: បាទ! នៅមន្ទីរពិការ ។

វណ្ណៈ: ពូនៅដល់ឆ្នាំណាដែលមានផ្លាស់ប្តូរទៅណាទៀតដែរ?

កបៈ: ខ្ញុំនៅហ្នឹងរហូតទាល់តែ៧៩ បានរត់បានរត់ ។

វណ្ណៈ: ចឹងនៅកន្លែងមន្ទីរពិការហ្នឹងអង្គការឲ្យធ្វើអីទៀតដែលឬមួយមិនមានធ្វើអីធំដុំទេ?

កបៈ: ពួកខ្ញុំនៅតាខ្មៅហ្នឹងក៏គេធ្វើបាបដែរ គេឲ្យស៊ីបាយលាយពោតធ្វើស្រូវធ្វើស្រែហូបខ្លួនឯង ។

វណ្ណៈ: អ្នកពិការហ្នឹង?

កបៈ: បាទ ។

វណ្ណៈ: ចឹងកាលនៅកងទ័ពពូបានហូបចុកគ្រប់គ្រាន់មិនអីទេ?

កបៈ: ហូបគ្រប់គ្រាន់ធម្មតាទេ កងទ័ពក្នុងពេលសង្គ្រាមមានពេលមាន មានពេលអត់ណាស់ វាជាធម្មតាទេ វាមិនមានបញ្ហាទេ ។

វណ្ណៈ: ចឹងនៅមន្ទីរពិការតាខ្មៅហ្នឹងពីណាជាអ្នកគ្រប់គ្រងពូ?

កបៈ: មន្ទីរតាខ្មៅហ្នឹងឈ្មោះតា ម៉ែនប្រធានមន្ទីរតាខ្មៅហ្នឹង ។

វណ្ណៈ: ចឹងតាម៉ែនហ្នឹង គាត់នៅរហូតដល់៧៩ដែរឬក៏គេ?

កបៈ: នៅរហូតដល់៧៩ដែរ តែយើងរត់ចេញពីតាខ្មៅមកជិនាន់៧៩ យើងរត់បែកគ្នាណាស់ ។

វណ្ណៈ: បាទ ។

កបៈ: មិនដឹងជាគាត់ទៅណាអីណី ខ្ញុំក៏បែកពីគាត់រតាត់រតាយគ្នាអស់ទៅ ។

វណ្ណៈ: ចឹងនៅកន្លែងពិការហ្នឹងមានបាត់ខ្លួនខ្លះដែលឬមួយមិនអីទេ?

កបៈ: សម័យនោះមានគេចាប់ដែរ ។

វណ្ណៈ: ពិការហើយត្រូវគេចាប់ទៀត?

កបៈ: ចាប់គេយកទៅសម្លាប់អស់ខ្ញុំអាណិតគាត់ដែរ ចាប់គេថាពិសេសខ្ញុំហ្នឹងគេត្រៀមនិងចាប់ដែរ កុំតែយួនចូលទាន់គេចាប់ខ្ញុំដែរ ។

វណ្ណៈ៖ ចឹងកាលហ្នឹងដោយសារថាគេចាប់មេចាប់អី នៅក្នុងសម័យបីឆ្នាំហ្នឹងពូបានដឹងហើយថាគេចាប់សោ ភឹម ក្រោយមកគេចាប់រស់ ញឹម គេចាប់គណៈតំបន់កុយ ធ្លួនអីបន្តបន្ទាប់អីចឹង?

កប៖ បាទ ។

វណ្ណៈ៖ តា ណាតប្រធានកងពលហ្នឹង?

កប៖ បាទ ។

វណ្ណៈ៖ កាលហ្នឹងពូដឹងដែលឬមិនបានដឹងទេកាលហ្នឹង?

កប៖ ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ៖ កាលហ្នឹងគោលការណ៍ថ្នាក់លើកាលជំនាន់ហ្នឹងថា តែគេចាប់មេហើយគេសំដៅចាប់កូនទៀតចឹងទោះបីជាអ្នកនោះពិការក៏ដោយក៏គេតាមចាប់បន្តទៀតដែរ?

កប៖ បាទ ។

វណ្ណៈ៖ ចឹងភាគច្រើនពូបានឃើញចឹងដែរ?

កប៖ បើនិយាយទៅពួកយើងនៅតាខ្មៅជំនាន់នោះខ្ញុំក៏ចង់កុនដែរ គេថាគោលនយោបាយគេធ្វើបដិវត្តកុំម្មុយនីស្តហ្នឹងណាស់ ។ គេធ្វើបដិវត្តកុំម្មុយនីស្តនិយមហ្នឹងគេបោសសម្អាតផ្ទៃក្នុងចង់និយាយថា គេបែកចែកវណ្ណៈភាពហ្នឹងមាន មានវណ្ណៈភាពមានកម្មករមានកសិករចឹងទៅហើយវណ្ណៈភាពបែងចែកមានប៉ុន្មានវណ្ណៈភាពនោះ វណ្ណៈភាពពិសេសដោយឡែកមានទាហានគ្រូបង្រៀននិសិត្សអីហ្នឹង ។

វណ្ណៈ៖ បាទ ។

កប៖ អាហ្នឹងគេហៅវណ្ណៈភាពពិសេសដោយឡែកវណ្ណៈភាពហ្នឹង វណ្ណៈភាពហ្នឹងដេកស្រួលស៊ីស្រួលចឹងខ្ញុំហ្នឹងចង់ចូលក្នុងក្រឡាហ្នឹងហើយ យើងជាអតីតនិសិត្សវិទ្យាល័យស៊ីសុវត្ថិវាចូលជានិសិត្សហើយ ។

វណ្ណៈ៖ បាទ ។

កប៖ និសិត្សហ្នឹងគេកំណត់ថា សម័យនោះគេបែងចែកនិសិត្សចាប់ត្រឹមថ្នាក់ទី៩ ទី៩ បើយើងគិតទៅវាស្មើនិងទី៨ ទី៨យើងសព្វថ្ងៃនេះ ទី៩ សង្គមរាស្ត្រនិយមហ្នឹងចាប់ពីថ្នាក់ទី៩ គេចាត់ទុកជាអនុធនសិស្ស គេហៅថាពួកអនុធនសិស្សហើយ ។

វណ្ណៈ៖ បាទ ។

កប៖ ចឹងខ្ញុំវាលើសហ្នឹងបន្តិចទៀតផង ខ្ញុំចឹងជាអនុធនហើយចឹងជាកូនសិស្សគេត្រូវដោះស្រាយហើយ ។

វណ្ណៈ៖ បាទ ។

កបៈ	ប៉ុន្តែដូចជាសំណាងឃួនបុកចូលមកខ្ញុំបានរួចខ្លួនដែរ ។

វណ្ណៈ	បាទ ។

កបៈ	កុំអីប្រហែលជាខ្ញុំឆ្លងមិនផុតក៏មិនដឹង ។

វណ្ណៈ	បាទ! តែនៅឆ្នាំ៧៧-៧៨នេះមានជ្រើសរើសអ្នកពិការមួយចំនួនពីតាខ្មៅហ្នឹងមកឲ្យនៅខាងបាត់ដំបងអីចឹងមានដែរ តែកាលហ្នឹងពូមានបានមកទេចឹង?

កបៈ	ខ្ញុំអត់បានមកទេ ។

វណ្ណៈ	ចឹងពូនៅហ្នឹងរហូតដល់៧៩?

កបៈ	បាទ ។

វណ្ណៈ	ចឹងពូមានបានដឹងទេ ជំនាន់បីឆ្នាំហ្នឹងថាសម្តេចសីហនុនៅក្នុងវាំង កាលហ្នឹងគេមានប្រាប់ឲ្យបានដឹងទេ?

កបៈ	អត់ដឹងទេ និយាយរួមពត៌មានសំខាន់ៗគេមិនបានបើទូលាយដូចសព្វថ្ងៃនេះទេ ពត៌មានសំខាន់ៗណាស់ ។

វណ្ណៈ	បាទ ។

កបៈ	គេបិទហើយចឹងយើងនៅតាខ្មៅហ្នឹងគ្មានអីស្តាប់ទេ គ្មានវិទ្យុអីស្តាប់ទេ ស្តាប់ហ្នឹងតាមវិទ្យុហ្នឹងយើងតតាមខ្សែដីខ្សែអាកាសបានតែស្តាប់ចំរៀងគេតិចៗថ្ងៃល្ងាចដែលយើងឡើងពីធ្វើការហ្នឹងណាស់ ។

វណ្ណៈ	បាទ ។

កបៈ	ពត៌មានជំនាន់នោះខ្ញុំគិតថាវាគ្មានពត៌មានអី ។

វណ្ណៈ	ពូគិតថាមកពីអត់មានពត៌មាន អត់មានកាសែត អត់បើកទូលាយដូចជាការផ្សព្វផ្សាយតាមវិទ្យុឬក៏ស្ទីបញ្ហាប្រព័ន្ធផ្សព្វផ្សាយហ្នឹងហើយបានជាមួយមនុស្សស្លាប់ច្រើនឬមួយយ៉ាងម៉េច បើតាមពូគិត?

កបៈ	បើតាមខ្ញុំយល់សម័យហ្នឹងវាគ្មានតុលាការ អ្នកណាមានអំណាចគឺអ្នកហ្នឹងអ្នកណាធ្វើមេគឺអ្នកហ្នឹងមានអំណាច អំណាចនៅលើគេហ្នឹងតែម្តង ។

វណ្ណៈ	បាទ ។

កបៈ	គេចង់យកពីណាទៅដាក់ពីណាក៏បានដែរ គេមានអំណាចហើយ អំណាចនៅលើបុគ្គលមិនចឹងជំនាន់នោះដែលខ្ញុំយល់ ។

វណ្ណៈ	បាទ ។

កបៈ អំណាចនៅលើបុគ្គលអំណាចគ្មាននៅលើតុលាការ គ្មានអំណាចនៅលើច្បាប់ទេ សម័យនោះខ្ញុំដឹងថាចឹង ។

វណ្ណៈ បាទ ។

កបៈ ព្រោះខ្ញុំដេកគិតថា ខ្ញុំដេកស្តាប់វិទ្យុអីចឹងទៅឃើញគេរៀបចំសភាដែលយើងខ្ញុំបានវិទ្យុហ្នឹងនិយាយរួមវិទ្យុសល់ពីកាលពីកងទ័ពម៉ាកណាស់សូណាល់អាថ្មពីរគ្រាប់ជំនាន់មុននោះ ។ គេអត់មានដកទេ យើងពិការចឹងគេឲ្យយើងយកមកប្រើចុះ ខ្ញុំបានអាហ្នឹងមួយគ្រាន់តែស្តាប់ពត៌មានដឹងថាថ្ងៃគេបោះឆ្នោតជ្រើសរើសតំណាងសភាអីស្តាប់តាមវិទ្យុថ្ងៃ២០ខសភានោះណាស់ ។

វណ្ណៈ បាទ ។

កបៈ ហើយនៅចាំចំរៀងនោះទៀតនោះ ។

វណ្ណៈ ចឹងយើងអាចលួចបើកស្តាប់វិទ្យុបានខ្លះៗ ?

កបៈ អត់ទេ យើងបើកស្តាប់វិទ្យុរបបកម្ពុជាប្រជាធិបតេយ្យគេដាក់នៅភ្នំពេញហ្នឹង គេមិនផ្សាយពត៌មានគេមិនផ្សាយផ្សេងៗនៅក្នុងប្រទេស ។

វណ្ណៈ បាទ ។

កបៈ ចឹងថ្ងៃសំខាន់ៗគេផ្សាយពត៌មានថ្ងៃហ្នឹងថ្ងៃ២០ខសភាជាបោះឆ្នោតជ្រើសតាំងសភាតំណាងប្រជាជនហើយ ។

វណ្ណៈ បាទ!ចឹងកាលហ្នឹងតា នួន ជា ជាប្រធានសភា?

កបៈ បាទ ។

វណ្ណៈ ចឹងពូដឹងចឹងដែរ?

កបៈ ដឹងយើងបានស្តាប់វិទ្យុ ។

វណ្ណៈ ចឹងកាលហ្នឹងដោយសារថាអត់មានតុលាការអីចឹងគិតថា ថ្នាក់លើថ្នាក់ដឹកនាំកំពូលដូចថាមិនបានរៀបចំឲ្យបានជិតដល់ដូចថាប្រព័ន្ធផ្សព្វផ្សាយចឹងជាកំហុសរបស់គាត់ឬមួយជាគំនិតរបស់គាត់ចង់ធ្វើសង្គមមួយឲ្យវាស្អាតស្អំយ៉ាងម៉េចបើតាមពូយល់?

កបៈ បើតាមខ្ញុំយល់ចំណុចហ្នឹងគាត់វាខ្វះបញ្ហាផ្សព្វផ្សាយពត៌មានសារណៈហ្នឹង វាគ្មានតែម្តងចឹងការទទួលពត៌មានអីផ្សេងៗពីខាងក្នុងខាងក្រៅអីយើងមិនដឹង ។

វណ្ណៈ ចឹងពូមានដឹងថា នៅក្នុងសម័យបីឆ្នាំហ្នឹងមានដឹងថានៅតាមជនបទហូបបបរអត់បាយកន្លែងខ្លះមានទៅកន្លែងខ្លះអត់ទៅហើយមានកន្លែងខ្លះសម្លាប់មនុស្សចឹងទៅ ពូមានបានដឹងទេកាលហ្នឹងឬក៏មិនបានដឹងទេ?

កបៈ	ខ្ញុំនិយាយត្រង់ទៅកាលហ្នឹង និយាយរួមផ្នែកកងទ័ពមិនថាអ្នកពីការប្តូកងទ័ពទេ គឺអត់ដឹងទេ យើងនៅមន្ទីរពិការយើងនៅអត់មានបានដើរទៅណាទេ ។

វណ្ណៈ	ខ្ញុំជឿចឹងមែនព្រោះគាត់មិនបានចេញមកខាងក្រៅ?

កបៈ	បាទ ។

វណ្ណៈ	សុំទៅលេងផ្ទះគេមិនឲ្យទៅផង?

កបៈ	គេមិនឲ្យច្បាប់ មិនមានច្បាប់ដាច់ខាតយើងនៅកន្លែងណាយើងនៅកន្លែងហ្នឹង ចឹងសភាពការណ៍នៅតាមមូលដ្ឋាននៅតាមឃុំអីខ្ញុំអត់មានដឹងទេ ។

វណ្ណៈ	បាទ ។

កបៈ	ដឹងតែកន្លែងខ្លួននៅផ្ទាល់តែម្តង ។

វណ្ណៈ	ចឹងមន្ទីរតាខ្មៅហ្នឹងនៅម្តុំណាពូ?

កបៈ	ខ្ញុំធ្លាប់នៅក្បាលស្ពានព្រែកហូរក៏ធ្លាប់នៅ ទៅចុះតាមទំបន់ព្រែកត្នោតមកកើតមកព្រៃរាំងក៏ខ្ញុំធ្លាប់នៅ ក្រពើហាក៏ខ្ញុំធ្លាប់នៅ វត្តក្រពើហា ។

វណ្ណៈ	បាទ ។

កបៈ	ហើយភូមិកំពង់សំណាញ់ក៏ខ្ញុំធ្លាប់នៅ មួយចំណុចហ្នឹងនិយាយរួមបរវេនរបស់មន្ទីរពិការហ្នឹងចុះចាប់ពីស្ពានព្រែកហូ រហូតទល់និងវត្តក្រពើហាពេទ្យឆ្ងួតហ្នឹងណាស់ ។

វណ្ណៈ	បាទ ។

កបៈ	ហើយចុះទៅកើតត្រង់ចឹងទៅ ទៅទល់ផ្លូវយើងកាត់តាមរោងចក្រកង់ឡានហ្នឹងមកត្បូងចឹងមកមកចាប់ផ្លូវយើងព្រែកត្នោតចុះទៅព្រែកសំរោងណាស់ ចឹងបរវេនហ្នឹងជាមន្ទីរពិការទាំងអស់ហ្នឹង ។

វណ្ណៈ	ចឹងនៅកន្លែងមន្ទីរពិការហ្នឹងមានលេខកូតទេ ដូចថាជាមន្ទីរលេខប៉ុន្មាន?

កបៈ	មន្ទីរ២១០ ។

វណ្ណៈ	ចឹងមន្ទីរ២១០?

កបៈ	បាទ ។

វណ្ណៈ	ចឹងមន្ទីរ២១០ហ្នឹង គ្រប់គ្រងដោយពីណា?

កបៈ	តា ម៉ន មុនតា ម៉នទៀតមានតា សេរី តា សេរីសម័យហ្នឹងគេចាប់គាត់យកទៅសម្លាប់បាត់ហើយ ។

វណ្ណៈ	បាទ ។

កបៈ ហើយខ្ញុំដឹងរឿងចាប់តា សេរី រឿងតា សេរីគាត់អត់ឲ្យមិត្តយើងធ្វើស្រែទេ គាត់មិនឲ្យទេអ្នកពិការ ។

វណ្ណៈ បាទ ។

កបៈ គាត់មិនឲ្យធ្វើស្រែទេ គាត់សុខចិត្តគាត់អតីមេចាស់គាត់ស្គាល់គេច្រើនណាស់ គាត់ទៅសុំអង្ករសុំអីគេពីកន្លែងកង់ទ័ពកងពលលិចកើតបានចិញ្ចឹមអ្នកពិការហ្នឹងគ្រប់គ្រាន់ហើយអត់មានពិបាកទេ ចឹងទៅគេចោទថា តា សេរីហ្នឹងក្បត់បក្ស តា សេរីហ្នឹងមិនចូលរួមកសាងជាតិ មិនរួមចំណែកកសាងប្រទេសនោះ គេចាប់គាត់យកទៅវៃចោលបាត់ទៅ បាត់តា សេរីទៅបានមានតា ម៉នមក តា ម៉នមកគៀបពួកយើងហើយអាហ្នឹង ឲ្យធ្វើស្រែអ្នកពិការដាច់ជើង ជើងត្រង់ឲ្យចុះភក់ពង្រៀបដីធ្វើស្រែទាំងអស់ ។

វណ្ណៈ តាមពិតទៅមនុស្សដែលពិការហើយមិនត្រូវឲ្យធ្វើមែនតាមច្បាប់?

កបៈ បាទ ។

វណ្ណៈ តា សេរីគាត់ធ្វើត្រូវតែអង្គការមិនបានពេញចិត្តគាត់ទេ?

កបៈ មិនពេញចិត្តទេ ព្រោះគេចោទគាត់ថា គាត់ហ្នឹងប្រឆាំងនិងគោលការណ៍ដែលកសាងជាតិនោះណាស់ គាត់មិនបានរួមចំណែកកសាងប្រទេសទេ ។

វណ្ណៈ តែគាត់អាចគិតឃើញថា អ្នកពិការនិងហើយខំតស៊ូបានភ្នំពេញហ្នឹង ចឹងហើយគ្នាពិការហ្នឹងគួរតែឲ្យគ្នាសម្រាកឲ្យគ្នានៅស្រួលដែរ?

កបៈ បាទ ។

វណ្ណៈ តែអង្គការមិនបានគិតចឹងទេ?

កបៈ មិនបានគិតចឹងទេ ។

វណ្ណៈ ចឹងកាលហ្នឹង តា សេរីហ្នឹងគាត់តវ៉ាជាមួយថ្នាក់លើចឹង?

កបៈ បាទ ។

វណ្ណៈ ចឹងគេចាប់ខ្លួនគាត់ទៅ?

កបៈ គេចាប់ទៅ ។

វណ្ណៈ ចឹងក្រោយមកតា ម៉នមកគាត់គៀបឲ្យធ្វើការធ្វើស្រែហ្នឹង?

កបៈ ធ្វើស្រែធ្វើចំការដាំចេកដាំអំពៅដាំដំណាំគ្រប់សព្វគ្នានពេលទំនេរទេ សូម្បីតែពិការហើយក៏គេធ្វើបាបដែរ ។

វណ្ណៈ ចឹងការហូបចុកមានខ្វះខាតខ្លះដែរ?

កបៈ ខ្វះមានខ្វះខាត ពួកខ្ញុំ ខ្ញុំប្រាប់ប្អូនឯងពួកខ្ញុំមួយកងខ្ញុំហ្នឹងវាមានគ្នា៤០នាក់ហើយខ្ញុំជាមនុស្ស

មួយដែលប្រឆាំងនិងគេ ។

វណ្ណៈ	បាទ ។

កបៈ	ប្រឆាំងនិងគេ គេដកខ្ញុំចេញពីព្រែកប្ញស្សីគេយកខ្ញុំទៅនៅអីព្រែករាំងនោះ មួយក្រុមខ្ញុំហ្នឹង ។

វណ្ណៈ	បាទ ។

កបៈ	គេមិនឲ្យមកហូបបាយកន្លែងរួមទេ ពួកខ្ញុំហ្នឹងណាស់ ។

វណ្ណៈ	បាទ ។

កបៈ	គេឲ្យចុងភៅដឹកយកទៅឲ្យ ដឹកយកទៅឲ្យហ្នឹងគឺយើងបានតែមួយវែកម្នាក់ទេបាយលាយពោត ពោតប្រហែលជា៧០ភាគរយ ពោតហ្នឹងដាក់ទាំងមូលទៀត ។

វណ្ណៈ	ចឹងពោតដាក់ទាំងមូលទៀត?

កបៈ	បាទ!ពោតដាក់ទាំងមូលទៀត ហើយពោតហ្នឹងដាក់៧០ភាគរយនៃអង្ករហើយបើយើងហូប មិនគិតអ្នកក្រោយគ្មានបានស្គាល់បាយទេ ចឹងយើងបានតែមួយចានចង្កឹះម្នាក់ទេបាយ ។

វណ្ណៈ	បាទ ។

កបៈ	ដួសស្មើៗគ្នាយើងជុំគ្នាមកដាក់មកហើយសម្លហ្នឹងហើយពួកខ្ញុំហ្នឹងជាអ្នករកត្រីផ្គត់ផ្គង់អង្គភាព ពិការតាខ្មៅហ្នឹងហើយ ។

វណ្ណៈ	បាទ ។

កបៈ	ចឹងគេស្ទូយកមកឲ្យគេស្ទូកាកល្ហុងបណ្ដែតទឹករហេរហាលត្រីឃើញអណ្ដែតដ្ឋីងដុងៗ ហើយត្រី យើងដឹកយកទៅឲ្យកន្លែងចង្ក្រានបាយហ្នឹងមួយថ្ងៃ៤០០ទៅ៥០០គីឡូ ។ ត្រីដែលយើងរក បាន អង្គភាពរកបានសម្រាប់គ្រប់គ្រងអង្គភាពមន្ទីរហ្នឹងទាំងមូល ។

វណ្ណៈ	បាទ ។

កបៈ	យើងដឹកកង់ដឹកអីយកទៅឲ្យហ្នឹង មួយថ្ងៃពី២០០គីឡូទៅ៣០០គីឡូ ។

វណ្ណៈ	បាទ!ចឹងត្រីកាលហ្នឹងសម្បូរសឹងអីហ្នឹង?

កបៈ	ចុះត្រីនៅព្រែករាំងនៅព្រែកហូរយើងនេះ ខុះស្អីលោកអើយត្រីយកទៅបារ៉ែនដើមពោធិ៍អី យើងដាក់ចំរះទៅក្នុងមួយចំរះមានមួយគោនទៅពីរគោនត្រីនោះ ។

វណ្ណៈ	បាទ ។

កបៈ	កាលហ្នឹងមិនដឹងជាគេយកទៅណាខ្ញុំក៏វាមិនដឹងដែរ ហើយខ្ញុំហ្នឹងគឺអ្នកដែលស្មោះត្រង់ជាមួយ ខ្ញុំផ្ដាច់ជាមួយខ្ញុំហើយណាស់ ។

វណ្ណៈ	បាទ ។

កបៈ ខ្ញុំថាឥឡូវគេឲ្យយើងធ្វើការគ្មានម៉ោងសម្រាកទេ ពួកខ្ញុំហ្នឹងណាស់ ខ្ញុំជាមនុស្សមួយទំនាស់នៅក្នុងហ្នឹង ទំនាស់អីទំនាស់រឿងជីវភាព បេះគេលើកគោលការណ៍គេលើករឿងបញ្ហាហ្នឹងគេគៀបខ្ញុំ គេដកសេចក្ដីទុកចិត្តខ្ញុំហ្នឹងហើយគេពិន័យខ្ញុំដាក់ទណ្ឌកម្មខ្ញុំនិងណាស់ ។

វណ្ណៈ បាទ ។

កបៈ ដីហ្នឹងនៅខាងក្រោយព្រែកឫស្សីចំការក្រូច ចំការក្រូចហើយខ្ញុំបានទទួលគា ម៉ុកគាត់បានទៅនិយាយនៅវត្តព្រែកឫស្សីគាត់ថាអ្នកពិការមិនបាច់ធ្វើស្រែទេ ចាំគាត់ចិញ្ចឹមគាត់ថាចឹង ។

វណ្ណៈ បាទ ។

កបៈ អ្នកពិការចាំគាត់ចិញ្ចឹមធ្វើតែចំការ មើលតែចំការខ្នុរ ចំការល្មុត ចំការមាន ចំការអីហ្នឹងទៅចឹងគា ម៉ែនគាត់មានគោលការណ៍មួយថា រួមចំណែកកសាងប្រទេសឲ្យសកម្មដើម្បីគាត់មានមុខមានមាត់ណាស់ ។ ចឹងគាត់យកកំលាំងគាស់ចំការក្រូចហ្នឹង គាស់ចំការក្រូចហ្នឹង ។

វណ្ណៈ បាទ ។

កបៈ រំលើងក្រូចពីដីខ្ពស់ដាក់មកដីទាបហើយយកដីក្រូចហ្នឹងពង្រៀបធ្វើដីស្រែ ចឹងពួកខ្ញុំហ្នឹងមានទំនាស់ហើយអន្តភាពគាខ្មៅអ្នកនៅមានជើងពិការមែនតែគ្រាន់វាមិនដាច់ជើងដាច់ដៃ ។

វណ្ណៈ បាទ ។

កបៈ មានជើងត្រង់ដៃត្រង់អីចឹងគឹកងខ្ញុំហ្នឹងហើយ ដែលជាអ្នកពង្រៀបដីហ្នឹងនោះ ចឹងខ្ញុំលើកខ្ញុំលើកហេតុផលថា ខ្ញុំថាខាងលើមិនឲ្យធ្វើស្រែទេឲ្យតែក្រូចឥឡូវមិនត្រឹមថែក្រូចគាស់ក្រូចគាស់ពីដីខ្ពស់មកដាក់ដីទាបវាមិនរស់ទេ វាងាប់ហើយ ។

វណ្ណៈ បាទ ។

កបៈ ចឹងដីទាបហ្នឹងមិនពង្រៀបធ្វើស្រែ ចាំពង្រៀបនេះអីមិនឃើញទេ វាខុសចឹងខ្ញុំលើកហេតុផលគវ៉ាក្នុងហ្នឹងមិត្តយើងនៅជាមួយខ្ញុំមានអាវ៉ាន់ខ្វេ អាផន រិន វ៉ាន់ ខ្វិត មានវ៉ាន់ខ្វេ វ៉ានខ្វិតមានផន រិនហើយនិងផន ទ្រព្យនៅជាមួយខ្ញុំហ្នឹង ។

វណ្ណៈ បាទ ។

កបៈ សុទ្ធអតីតធ្លាប់រស់នៅជាមួយគ្នាកាលពីសង្គ្រាម រួមគ្នាបញ្ចេញមតិប្រជុំរហូតដល់ម៉ោង១២កន្លះ គា ម៉ែនដោះស្រាយមិនចេញទះតុដួងបិតអន្តប្រជុំបណ្ដោយ ក្រោយមកបានតែ៥ថ្ងៃគេមកចាប់ពួកហ្នឹងអស់ ។

វណ្ណៈ បាទ ។

កបៈ ចាប់យកទៅអស់ស្លាប់បាត់ទៅ គេយកទៅវៃចោលអស់ខ្ញុំអាណិតមិត្តយើងណាស់ អ្នកពិការគេចាប់យកទៅវៃចោល ។

វណ្ណៈ	បាទ ។

កបៈ	រឿងអីរឿងប៉ុណ្ណឹង ។

វណ្ណៈ	ចឹងពូមានសំណាងដែលអត់អី?

កបៈ	បាទ ។

វណ្ណៈ	ចឹងតា ម៉ុកចុះមកប្រាប់ថាមិនឲ្យធ្វើការហ្នឹង ប្រហែលជាឆ្នាំណាពូអាចចាំបានទេ?

កបៈ	ឆ្នាំ៧៦ ឆ្នាំ៧៦គាត់មកប្រាប់ គាត់ថាអ្នកពិការចាំគាត់ចិញ្ចឹមមិនបាច់ឲ្យធ្វើទេ ហើយឲ្យហូបមួយថ្ងៃបីពេលទៀតគាត់និយាយចឹង ។

វណ្ណៈ	បាទ ។

កបៈ	ហើយឃើញមែន មិនមែនតែគាត់ថាទេ ពួកខ្ញុំមិនឃើញទេណាស់ ខ្ញុំនៅព្រែកប្ញស្សីហ្នឹង ហើយឃ្លាំងនៅព្រែកប្ញស្សីសម្រាប់ដាក់អង្ករពួកខ្ញុំអ្នកលើកដាក់នោះ ឡានសេអ៊ីមសេរបស់អាមេរិចកាំងដឹកអង្ករមកបីឡាន ។

វណ្ណៈ	បាទ ។

កបៈ	សម្រាប់ឲ្យហូបក្នុងមួយខែណាស់ យើងគិតអង្ករបីឡានហ្នឹងហូបមួយខែអ្នកពិការហ្នឹងហូបបីពេលមិនអស់ទេ តែតា ម៉ុនគាត់អត់ទទួលទេ គាត់ថាគាត់ម្ចាស់ការបានហើយអង្គភាពគាត់ចឹងបីឡានសូមជូនទៅខាងលើវិញ រួមចំណែកកសាងជាតិ ។

វណ្ណៈ	ចឹងគាត់ឈ្លៀតយកគួរចឹងទៀត?

កបៈ	បាទ!គាត់យកគួរចឹងទៀត គេយកមុខយកមាត់គេនោះ អ្នកពិការខ្វះស្រក់ទឹកភ្នែក ។

វណ្ណៈ	បាទ ។

កបៈ	ខាងលើឲ្យមកហើយគាត់ថាអង្គភាពគាត់ម្ចាស់ការបានហើយ អត់អីទេចឹងអង្ករហ្នឹងសូមជូនទៅខាងលើវិញរួមចំណែកកសាងប្រទេស ។

វណ្ណៈ	ចឹងតា ម៉ុកចុះមកឆ្នាំ៧៦ក្រោយមកតា ម៉ុកមានចុះមកទៀតទេ?

កបៈ	ចុះមកចុះអ្នកពិការនៅក្នុងក្របខ័ណ្ឌភូមិភាគរបស់គាត់ហ្នឹង គាត់គ្រប់គ្រងបីបាច់ថែរក្សាប៉ុន្តែអ្នកគ្រប់គ្រងផ្ទាល់ហ្នឹងវាយកមុខយកមាត់វាធ្វើបាបអ្នកពិការ ។

វណ្ណៈ	បាទ ។

កបៈ	បើតាមតា ម៉ុកគាត់មិនធ្វើបាបទេ គាត់ចិញ្ចឹមសូម្បីតែខោអាវល្អៗដែលតា ម៉ុកគាត់យកមកឲ្យអតីតមេទ័ពចាស់ៗដូចខ្ញុំចឹងណាស់ តា ម៉ុនមិនយកទៀតឲ្យទៅវិញទៀតសុខចិត្តឲ្យពាក់អាវប្រឌឹបយើងមានពណ៌ពីរបីនោះណាស់ ។

វណ្ណៈ	បាទ ។

កបៈ	មានអាខ្មៅផងមានអាត្រួយចេកផង  អាមុខនេះចេកស្ងោរទៅអាខាងនេះទៅពណ៌ខ្មៅប្រឡេកប្រឡាកចឹងខេអាវល្អៗរបស់មេៗទ័ពដែលតា  ម៉ុកគាត់យកមកឲ្យតា  ម៉ន់គាត់មិនយកទេ  គាត់ថាជូនទៅលើវិញ ។

វណ្ណៈៈ	ចឹងតាម៉នហ្នឹងគាត់លមកពីខាងណាដែលគាត់មកពីខាងតាកែវដែលឬមកពីខាងណា?

កបៈ	តា  ម៉នហ្នឹងពីដើមតាមខ្ញុំដឹងប្រវត្តិគាត់  តា  ម៉នហ្នឹងនៅក្នុងកងពលទី១ ។

វណ្ណៈៈ	នៅកងពលទី១ហ្នឹងខាងភូមិភាគអីទៅ?

កបៈ	កងពលទី១ហ្នឹងនៅខាងជើងផ្លូវលេខ៤  តែមិនដឹងជានៅក្នុងភូមិភាគអីខ្ញុំដឹងមិនច្បាស់ដែរ ព្រោះនៅតាខ្មៅហ្នឹងអ្នកពិការវាចំរុះមានបីកងពល  កងពលទី២និងកងពលទីពារបស់និរតីហើយ កងពលទី១  មិនដឹងជា  អ្នកងពលទី១ហ្នឹងប្រហែលជាអ្នកពិការហ្នឹងគេផ្ញើណាស់  អត់ទាន់មានមន្ទីរដាក់អ្នកពិការពួកកងពលទី១ហ្នឹងគេផ្ញើអ្នកពិការនៅហ្នឹងដែរ ។

វណ្ណៈៈ	បាទ ។

កបៈ	តា  ម៉នហ្នឹងបើតាមខ្ញុំដឹងប្រវត្តិគាត់ធ្វើប្រធានមន្ទីរបានហ្នឹងគាត់សម័យហ្នឹងកាលគាត់នៅកងទ័ពគាត់អាចជាសមាជិកកងពល ។

វណ្ណៈៈ	បាទ ។

កបៈ	ហើយយើងឋានៈជាវរៈសេនាតូចអីយើងមិនអាចបានធ្វើប្រធានមន្ទីរទេ  ព្រោះមានគេលើយើង ។

វណ្ណៈៈ	បាទ ។

កបៈ	គេមានសមាសភាពលើយើងគេគ្រប់គ្រងមន្ទីរ  យើងថ្នាក់ប្រធានវរៈសេនាតូចនៅកងទ័ពយើងមកនៅមន្ទីរមានកងទ័ពណាកាន់  យើងគ្រប់គ្រងអ្នកពិការ២០ទៅ៣០នាក់ទៅ ។

វណ្ណៈៈ	បាទ ។

កបៈ	ជាមេកងមេកើយអីចឹងទៅណាស់ ។

វណ្ណៈៈ	ចឹងតា  ម៉នហ្នឹងគាត់កាន់ដល់៧៩ចប់ចឹងដែរ?

កបៈ	បាទ ។

វណ្ណៈៈ	ចឹងនៅពេលចប់៧៩ហ្នឹងពូមិនទាន់រៀបការទេ?

កបៈ	ខ្ញុំរៀបការហើយ ។

វណ្ណៈៈ	ចឹងអង្គការរៀបឲ្យ?

កបៈ	បាទ ។

វណ្ណៈៈ	នៅឆ្នាំណាដែលអង្គការរៀបឲ្យ?

កបៈ ខ្ញុំរៀបនៅឆ្នាំ៧៨ ។

វណ្ណៈ ចឹងកាល៧៨ហ្នឹងពូពេញចិត្តមីងឬមើលឃើញគ្នាឬយ៉ាងម៉េច អង្គការចាប់ដាក់ឲ្យ?

កបៈ អត់ទេ ពេញចិត្តដែរ តា ម៉ុកគាត់ឲ្យរើសដែលហ្នឹង មិនមែនគេចាប់បង្ខំទេ ។

វណ្ណៈ ចឹងមានតា ម៉ុក ចូលរួមដែរ?

កបៈ គាត់មិនចូលរួមទេ គាត់ឲ្យមេបន្ទុបន្ទាប់ជាអ្នករៀបចំ ប៉ុន្តែគេយកនារីមកឲ្យយើងមើលចឹងទៅណាស់ ។

វណ្ណៈ បាទ ។

កបៈ យើងពេញចិត្តអ្នកណាយើងប្រាប់គេទៅ ពេលរៀបចំមានមេខាងនារីហ្នឹងគេប្រាប់ថា មេខាងយុទ្ធជនហ្នឹងប្រាប់ថាខ្ញុំស្រឡាញ់នារី«ខ»ចឹងទៅណាស់ ទៅប្រាប់អង្គភាពនារីចឹងទៅ ហើយនារីៗគេទៅប្រាប់នារី«ខ»ថាខ្ញុំឈ្មោះនេះអង្គភាពនេះស្រឡាញ់មិត្តឯង ។

វណ្ណៈ បាទ ។

កបៈ មិត្តឯងអាចទទួលបានដែលអត់ បើខាងនារីគេថាទទួលបាន ចឹងគេរៀបចំឈ្មោះទៅដល់ថ្ងៃយើងរៀបចំផ្សំផ្គុំគ្រួសារហ្នឹងគេយកឈ្មោះហ្នឹង គុម្ពួយអង្គុយទល់មុខគ្នាចឹងទៅ ។

វណ្ណៈ ចឹងកាលពូរៀបការហ្នឹងមានប៉ុន្មានគូរដែរ?

កបៈ មាន៤០គូរ ។

វណ្ណៈ ៤០គូរតាមពូដឹងនៅជុំគ្នាទាំងអស់ទេ?

កបៈ នៅជុំគ្នាទាំងអស់ អត់មានបែកបាក់ទេ ជុំគ្នាទាំងអស់ ។

វណ្ណៈ អត់មានពេល៧៩ហើយលែងគ្នាវិញទេ?

កបៈ មានមួយគូរលែងគ្នាដែរ ។

វណ្ណៈ ចឹងមីងជាអ្នកស្រុកណាដែរ?

កបៈ នៅស្រុកជាមួយគ្នាដែរ នៅស្រុកត្រាំកក់ដែលតែនៅឃុំខុសគ្នា ។

វណ្ណៈ បាទ ។

កបៈ ពីដើមគេដាក់ឃុំត្រពាំងធំ ឥឡូវគេដាក់ឃុំអូរសោយ ស្រុកត្រាំកក់ដូចគ្នា ។

វណ្ណៈ បាទ ។

កបៈ គាត់នៅម្តុំគ្នោតជុំ ។

វណ្ណៈ ចឹងពូស្គាល់តា ម៉ុកច្បាស់ដែរ?

កបៈ ស្គាល់ ។

វណ្ណៈ ចឹងតា ទិត?

កបៈ ស្គាល់ តែគ្រាន់ឮឈ្មោះថាស្គាល់ចឹងទេ តែមិនដែលឃើញមុខឃើញមាត់អីទេ មានឮឈ្មោះថា តា ទិតចឹងទៅ តែបើតា ម៉ុកខ្ញុំស្គាល់ ។

វណ្ណៈ បាទ!ចឹងតា វ៉ែនកូនប្រសារតា ម៉ុកហ្នឹងស្លាប់ឆ្នាំណាពូមានដឹងទេ?

កបៈ តា វ៉ែនហ្នឹងខ្ញុំនិយាយមិញ តា វ៉ែនហ្នឹងគាត់ជាមេទ័ពខ្ញុំពីដើមហើយហ្នឹង ។

វណ្ណៈ តែក្រោយមកគាត់មកកាន់ខាងហ្នឹងដែរ ខាងថ្មដាដែរ?

កបៈ បាទ!ជាមេទ័ពចាស់ខ្ញុំហើយហ្នឹង កាលជំនាន់ហ្នឹងនោះ ។

វណ្ណៈ បាទ ។

កបៈ ឥឡូវគាត់ស្លាប់បាត់ហើយ ។

វណ្ណៈ ចឹងកាល៧៩ វៀតណាមវ៉ៃចូលហ្នឹងយ៉ាងម៉េចបានជាពូមិនរត់ទៅស្រុកកំណើតភ័យខ្លាចយួនឬមួយយ៉ាងម៉េចកាលហ្នឹង?

កបៈ យើងមានគំនិតមួយដែលយើងខ្វលក្បាលមួយដែលយើងនៅចងចាំបានបានថា យួនដាំតែអុងនោះណាស់ ហ្នឹងហើយដែលដូចតាយើងតែងនិយាយប្រាប់ថា ពីជំនាន់ណាទេ យួនវាចាប់ខ្មែរបានហើយវាយកទៅកប់ត្រឹមកហើយយកក្បាលខ្មែរធ្វើថ្មចង្ក្រានដាំតែឲ្យចៅហ្វាយវាដឹកវាថាកុំរើប្រយ័ត្នក្រពុបតែអុងនោះ ។

វណ្ណៈ បាទ ។

កបៈ យើងភ័យខ្លាចត្រង់ហ្នឹងហើយដែលយើងមិននៅសុខចិត្តរត់មកចូលព្រៃនោះ ប្រជាជន៧៩ភាគច្រើនចឹង ។

វណ្ណៈ បាទ ។

កបៈ ចឹងបានជាអ្នកខ្លះមានប្រពន្ធកូនរងើររង៉ាករត់មកចូលព្រៃ រឿងអីរឿងខ្លាចអាយួនតែអុងហ្នឹងឯង ។

វណ្ណៈ ចឹងស្លាប់នៅពេលរត់ចូលព្រៃហ្នឹងច្រើនណាស់តាមមើល?

កបៈ បាទ ។

វណ្ណៈ ប្រហែលជារាប់ម៉ឺននាក់ដែរ?

កបៈ បាទ ។

វណ្ណៈ ព្រោះយើងរត់មកភ័យទោះបីជាយើងលីអង្ករមិនអាចលីបានច្រើនគីឡូដែរពូ?

កបៈ បាទ ។

វណ្ណៈ ហើយយើងចំណាយពេលរត់មកដល់ព្រំដែននេះដីរាប់រយគីឡូនោះ?

កបៈ អូ!រត់រាប់ខែនោះ ។

វណ្ណៈៈ ចឹងយើងរត់រាប់ខែចឹងយើងញ៉ាំយ៉ាងម៉េចគ្រាន់ ចឹងកាលពូចេញមកហ្នឹងទាំងកងអង្គភាពពូតែម្តងចេញមករត់ឬមួយជិះឡានអីកាលហ្នឹង?

កបៈ យើងអត់មានឡានទេ អ្នកពិការមានឡានណា ។

វណ្ណៈៈ ចឹងមានអ្នកពិការដាច់ជើងដាច់អីគ្នាធ្វើយ៉ាងម៉េចទៅពូ?

កបៈ ដាច់ជើងអត់មានមកទេ អត់មកទេមកយើងរត់ចេញពីតាខ្មៅ អ្នកខ្លះរត់ទៅផ្ទះទៅណាស់ តែខ្ញុំអត់ទៅផ្ទះទេ ខ្ញុំមិនទៅបណ្តោយយើងបានស្តាប់ដូចតាយើងគាត់ដំណាលប្រាប់ថា រឿងយួនដាំតែអុងហ្នឹងណាស់ វរះពោះញាត់ស្មៅអីចឹងប្រវត្តិសាស្រ្តជិនាន់មុនដែលគេចែងបានចារបានទុកអីហ្នឹង ។

វណ្ណៈៈ បាទ ។

កបៈ គេថាយួនហ្នឹងចាប់ខ្មែរយើងបានវះពោះច្រកស្មៅហើយ ចាប់ខ្មែរបានជាឈ្លើយសឹកហ្នឹងយកកប់ត្រឹមកហើយយកក្បាលហ្នឹងធ្វើក្បាលចង្ក្រានដាំតែអុង គេថាកុំរើប្រយ័ត្នកំពប់តែអុងយើងខ្លាចត្រង់ហ្នឹងយើងសុខចិត្តមកស្លាប់ក្នុងព្រៃទៅល្អជាងគេចាប់ធ្វើបាបទាំងរស់ចឹង ។

វណ្ណៈៈ បាទ!ចឹងពូរត់កាត់តាមផ្លូវជាតិណា?

កបៈ ខ្ញុំរត់ចេញមកតាមផ្លូវក្រូទូត កំពង់ទួលយើងហ្នឹងកាត់មកផ្លូវលេខ៤ យើងដើរកាត់វាលស្រែណាស់ ។

វណ្ណៈៈ បាទ ។

កបៈ មកឆ្លងផ្លូវលេខ៤ម្តុំយើងត្រឡាប់កាប់កង់បានមកជើងមក មកខាងទិវ៉ាល់អីមកចេះតែបុកមកទៀតមក មកគេឯងហូរហែរចឹងទៅ ។

វណ្ណៈៈ ចឹងពូធ្វើដំណើរតាមថ្នល់ខ្លះតាមវាលស្រែខ្លះ តាមព្រៃខ្លះចឹង?

កបៈ បាទ ។

វណ្ណៈៈ ចឹងការដើរទៅហ្នឹងមានគ្នាច្រើនដែរ?

កបៈ មានគ្នាច្រើនណាស់ រាប់ម៉ឺននាក់នោះ តែមិនមែនដើរជាប់គ្នាទេ ដូចជាអង្គភាពអូនឯងដើរដាច់ពូប្រហែលជាពីរទៅបីគីឡូទៅខ្ញុំនៅហ្នឹងមួយគីឡូឬ៥០០ម៉ែត្រទៀត ខាងក្រោយមានមួយអង្គភាពទៀតចឹងទៅ វាមិនមែនដង្ហែរគ្នាណា ខ្លះនៅត្រង់នេះ ខ្លះនៅត្រង់នោះចឹងទៅដើរទិសស្របគ្នាណាស់ ។

វណ្ណៈៈ បាទ!ចឹងកាលហ្នឹងពូមានកូនហើយនៅ?

កបៈ ខ្ញុំនៅទេ ។

វណ្ណៈៈ មិនទាន់មានទេ?

កបៈ មិនទាន់មានទេ ។

វណ្ណៈ បើមានក៏ពិបាករឿងកូនហ្នឹងដែរ?

កបៈ និយាយរួម៧៩ខ្ញុំរត់សំដៅទិសខាងលិចទាំងអស់ មនុស្សវាមកពពាក់ពពូនគ្នា យប់ឡើងយើងស្នាក់នៅតាមអន្តភាពតាមកងតាមក្រុមទៅតែវាជាប់គ្នា និយាយរួមទិសដៅតែមួយយើងយកគោលដៅតែមួយមកព្រំដែនលិចនោះណាស់ ។

វណ្ណៈ ចឹងនៅពេលដែលពូដើរចឹង ពូមានបានឃើញផ្ទាល់មនុស្សអត់បាយស្លាប់តាមផ្លូវ ហើយពូដើរហួសអីទៀតចឹងមានទេ?

កបៈ យើងកាល៧៩ហ្នឹង កំពង់តែរត់ហ្នឹងយើងមិនមានឃើញអ្នកស្លាប់ទេ ជិនាន់ខ្ញុំរត់ ប៉ុន្តែខ្ញុំឃើញស្លាប់និងភ្នែកគឺយើងដល់ព្រំដែន ។

វណ្ណៈ ចឹងមានមូលហេតុអីវិញបានជាដល់ព្រំដែនហើយស្លាប់?

កបៈ ដាច់បាយ ។

វណ្ណៈ ចឹងដាច់បាយស្លាប់?

កបៈ កាលណាយើងដាច់បាយដាច់ជាតិអង្ករដាច់ជាតិបាយចឹងទៅយើងហូបចំណីព្រៃមិនចឹង ។

វណ្ណៈ បាទ ។

កបៈ ហូបទំពាំងហូបក្រៃលលក ហូបនិយាយរួមស្លឹកឈើព្រៃណាដែលយើងធ្លាប់ដឹងហូបបានចេះតែហូបទៅមកធ្វើជាបបរព្រោងបបរអីដាក់អំបិលអីហូបចឹងទៅណា ដល់ខ្វះជីវជាតិបាយទៅមនុស្សកើតជាឈឺ ឈឺយើងអត់មានថ្នាំមិនស្លាប់ ។

វណ្ណៈ ចឹងកាលហ្នឹងទឹកតាមស៊ីងអីហ្នឹងមានទេ?

កបៈ មានយើងនៅជាប់ប្រភពទឹកប៉ុន្តែបញ្ហាសំខាន់អត់ថ្នាំនិងបាយហ្នឹងតែម្តង ។

វណ្ណៈ ចឹងទឹកកាលហ្នឹងយើងមានបានដាំអីទេ?

កបៈ ដាំយើងដាំ បើអន្តភាពនៅជាមួយខ្ញុំ ខ្ញុំដាំទឹកឲ្យហូបតែម្តង ។

វណ្ណៈ យើងចៀសវាងខ្លាចចាញ់?

កបៈ បាទ!ខ្លាចចាញ់ហើយអ្នកដែលរស់នៅទល់សព្វថ្ងៃដែលរស់នៅអនុវត្តតាមខ្ញុំហើយ ។

វណ្ណៈ បាទ ។

កបៈ ទី១ដាំទឹកហូប តែទី២កុំហូបត្រពាំង ត្រពាំងឫស្សីហ្នឹងហ្នឹងណាស់ មិនបានទេដាច់បាយអូនឯងជឿទៅ បើដាច់បាយដូច៧៩ហូបត្រពាំងតែបីដងគឺហើមបណ្តោយ ។

វណ្ណៈ បាទ ។

កបៈ ហើយហើមហើយចប់ហើយ ៧៩តែហើមដឹងថាចប់តែម្តង យើងអត់ថ្នាំចឹងសុខចិត្តអត់ទៅ ហូបត្រែលលក ហូបក្រចកអណ្តើក ហូបប្រក់ស្វា ហូបស្លឹកល្ងៀងអីចេះតែស្ងោហូបទៅណាស់ អត់អីទេអត់ហើមទេ។

វណ្ណៈ ចឹងកាលហ្នឹងពូមកដល់ព្រំដែនតែម្តងនៅឆ្នាំណា?

កបៈ ឆ្នាំ៧៩ហ្នឹង។

វណ្ណៈ ពូមកខាងព្រំដែនខាងណា?

កបៈ ខ្ញុំនៅនេះខ្ញុំរត់ចុះទៅដល់វត្តកំរៀង កំរៀងយើងស្រុកកំរៀងនេះ ខ្ញុំនៅវត្តកំរៀងហ្នឹង។

វណ្ណៈ ពូនៅស្រុកកំរៀងរហូតឬមួយផ្លាស់ប្តូរមកពីខាងណាដែរ?

កបៈ ក្រោយមកយើងចេះតែរំកិលទៀតទៅ យើងនៅកំរៀងហ្នឹងបានមួយខែកន្លះខែយួនវាបុកមកទៀតយើងរំកិលមកដើងទៀត រំកិលមកអូរចំលង យួនបុកមកទៀតយើងរំកិលមកអូររំលេកយួនបុកមកទៀតយើងរំកិលមកអូរប្រយុទ្ធ យួនបុកមកទៀតយើងរំកិលមកអូរទឹកស្អា យួនបុកមកទៀតយើងរំកិលដល់អូរល្ហុង យួនបុកមកទៀតយើងរំកិលដល់បារាំងធ្លាក់ យួនបុកមកទៀតយើងរំកិលមកដល់ចក្រីគីឡូ១២គីឡូ១៣គីឡូ១១ គីឡូ១០គីឡូ៩ទៅធ្លាក់ដល់បឹងបេងទៅមកទល់នៅម៉ាឡៃនៅហ្នឹង។

វណ្ណៈ ចឹងពូបាននៅម៉ាឡៃដែរ?

កបៈ នៅម៉ាឡៃនៅទល់ត្រឹមហ្នឹង ដល់ម៉ាឡៃកងទ័ពបន្ទាប់ពីនឹង ខត្តមសេនីយ៍ នី កន ហើយនឹងសុខ ភាព នឹងគេមេទ័ព គេចាប់ដៃសហការគ្នា គេចាប់ដៃគ្នាកាងជាប់ទៅ យួនបុកលែងកើតកន្លែងនឹងតំបន់រំដោះ អ្នកតស៊ូ នៅម៉ាឡៃនឹង ហើយនឹងកងពល៣២០នឹង គេចាប់ដៃគ្នាជាប់ទៅ កងទ័ព៣២កងពល គេចាប់ដៃគ្នាជាប់គេកាងជាប់។ គេពង្រឹកតំបន់រំដោះ ប្រជាជនគេឲ្យនៅជាប់នឹងអូរព្រំដែននឹងម៉ង។ ដល់ពេលនោះខែ១០ ៧៩ យើងនៅបានហើយ ដោយសារអីដោយសារ UNHCR គាត់ចុះទៅជួយអ្នកភៀសខ្លួនយើងនៅព្រំដែន គាត់យកអំណោយទៅឲ្យ ដល់ចឹងលែងអត់។ យើងលែងអត់ បាយហូបលែងខ្វះហើយ ប៉ុន្តែមនុស្សពេលដែលមិនទាន់បានគឺអគ្គភាពនឹងស្លាប់២នាក់។ មានបាយហូបស្លាប់២។

វណ្ណៈ ម៉េចបានស្លាប់?

កបៈ ក្រពះវាដាច់ជាតិបាយហើយអ្នកដែលស្លាប់ហ្នឹងមិនខ្វាចខ្ញុំ អ្នកដែលស្លាប់ខ្ញុំមិនស្លាប់ទេ។

វណ្ណៈ បាទ។

កបៈ យ៉ាងម៉េចក្រពះយើងដាច់ជាតិបាយ យើងដាំបាយយើងហូបឆ្អែតវាចុក ចុកស្លាប់មួយភ្លេចហ្នឹង។

វណ្ណៈ	ចឹងមានន័យថាហល់តែម្តង?

កបៈ	ហល់តែម្តង ខ្ញុំថាហូបចុកអត់មានរបបកំណត់ទេ ។ ព្រោះយើងពាក្យថាកាកបាទក្រហមនោះណាស់ នៅព្រំដែនកាកបាទក្រហមគាត់យកមកចែកទេ ហើយរបបគាត់ចែកមួយអាទិត្យម្តងមួយអាទិត្យមួយរបបហ្នឹងមានអង្ករ៣០គំប៉ុងក្នុងមួយនាក់ ។ គេឲ្យយើងហូបខ្ញុំថាខ្ញុំមិត្តឃាត់ទេ មិត្តទាំងអស់ហូបចុះ ប៉ុន្តែហូបបាយរឹងហើយស្រួយមុនដំបូងគឺបបរគោះរែកសិនហើយហូបតិចៗ ។

វណ្ណៈ	បាទ ។

កបៈ	យើងហូបញឹកយើងចេះតែហូបទៅ អ្នកធ្វើយ៉ាងនោះអត់មានស្លាប់សួរប្រពន្ធខ្ញុំ អាសៅមកមើលខ្ញុំហូបហើយចុកប្រកាច់យកបណ្តោយ ចុះបាយអស់មួយកំមែលដាក់មួយកំមែលទៀតទៅបណ្តោយ ។

វណ្ណៈ	បាទ ។

កបៈ	ចុកស្រែកពេញព្រៃហ្នឹងស្លាប់ប្រហែលជាបីម៉ោងស្លាប់អាហ្នឹងស្លាប់ដោយសារបាយ ។

វណ្ណៈ	ចឹងកាលហ្នឹងមិនទាន់មាន UNHCR ដូចថាចាញ់ អីច្រើនទេ?

កបៈ	កាលហ្នឹងចាញ់ខ្លាំងណាស់ បើអន្តភាពខ្ញុំនៅព្រំដែន, ខ្ញុំប្រាប់គ្រង់កុមារៗកំព្រាដែលវារត់បែកបាក់មេកើយមក ខ្ញុំប្រមូលយកទៅប្រហែលជាបាន៧០នាក់ កុមារអាយុជាង១០ឆ្នាំយកទៅនៅជាមួយខ្ញុំ ខ្ញុំអាណិត អាអ្នកដែលស្តាប់ខ្ញុំ វារស់ អាអ្នកដែលមិនស្តាប់ស្លាប់ ។ ពេលដែលវាស្លាប់ច្រើនពេកទៅ យើងវាពិបាក យើងកាចជើងក្រប យកអង្រឹងក្របសពចឹងហើយ កាច់ស្លឹកឈើក្របខ្វះ ។ ខ្មែរក្រហម ៧៩ ។

វណ្ណៈ	ពូនៅម៉ាឡៃឆ្នាំណាដល់ឆ្នាំណា?

កបៈ	ខ្ញុំតាំងពី៧៩រហូតដល់៨៤ ។

វណ្ណៈ	នៅម៉ាឡៃប្រធានកងពលពីណាគេ?

កបៈ	កាលនឹងយើងស្គាល់តែតាភាព ។

វណ្ណៈ	សុខ ភាព ក្រោយ?

កបៈ	បាទ!

វណ្ណៈ	ចុះតាហុងអី?

កបៈ	មុនដំបូងតាហុងៗ ។

វណ្ណៈ	បើតាកន គាត់នៅខាងកំរៀងទេ?

កបៈ	តាកន គាត់នៅខាងគេហៅកងពល៣២០ ប៉ុន្តែកងពល២នឹងចាប់ដៃគ្នាទេ សហការគ្នា ។

វណ្ណៈ	ខាងកំរៀង គាត់ គាកន?

កបៈ	គាកន គាត់ខាងសំពៅលូន។

វណ្ណៈ	ចឹងតាហុង សុខ ភាព អីកងពលលេខប៉ុន្មាន?

កបៈ	ខ្ញុំភ្លេចទៅហើយ ដូចកងពលលេខប៉ុន្មាន ប៉ុនខ្ញុំចាំបាន នី កន កងពល៣២០កាលនឹង។ សុខ (ភាព) ដូចកងពល៤០៥ ហើយក៏ប៉ុន្មានខ្ញុំភ្លេច។

វណ្ណៈ	ពូនៅម៉ាឡៃតាំងពី៧៩ ដល់៨៤?

កបៈ	បាទ!

វណ្ណៈ	ហើយពូមានរត់ទៅជំរំអីនឹងគេ?

កបៈ	អត់ទេ ខ្ញុំអត់។

វណ្ណៈ	អត់ទៅចូលជំរំ៨៥អី?

កបៈ	អត់។

វណ្ណៈ	ចុះពូកាល៧៩ ៨៤ ដោយសារពូពិការតាំងពី៧៥ ដល់ពេលពូទៅនឹងក៏ពូពិការដែរ ចឹងពូចូលទ័ពទៀត ឬក៏អត់?

កបៈ	អត់ទេ ខ្ញុំនិយាយដោយត្រង់សព្វថ្ងៃនេះ ខ្ញុំក៏ជានាយកសាលាទៀត។ ចឹងខ្ញុំឃើញក្មេងច្រើន ចឹងមានគំនិតពិភាក្សាជាមួយមេឃុំ មេភូមិនៅម៉ាឡៃនឹង រៀបចំជាសាលារៀនឲ្យក្មេងរៀន។ ខ្ញុំធ្វើគ្រូបង្រៀនបណ្តោយ។

វណ្ណៈ	ឆ្នាំណាៗ?

កបៈ	ឆ្នាំ៨០ខ្ញុំធ្វើគ្រូបង្រៀន តាំងពីនឹងមករហូត។

វណ្ណៈ	គ្រូបង្រៀន កាលនឹងបង្រៀនដោយមានទឹកចិត្តបង្រៀន អត់ទាន់មានបង្កើតជាក្រសួង?

កបៈ	អត់ទេៗ យើងធ្វើម៉េចឲ្យក្មេងបានស្គាល់ចេះអក្សរខ្មែរ ឲ្យកូនខ្មែរយល់ពីអក្សរសាស្ត្រខ្មែរ ហើយចេះអក្សរសាស្ត្រខ្មែរ ឲ្យវាស្គាល់ ក ខ គ ឃ ង។

វណ្ណៈ	កូនសិស្សប៉ុន្មាននាក់ដែរ ពូបង្រៀននឹង?

កបៈ	កាលខ្ញុំរៀន កូនសិស្សប្រហែល២០០នាក់នឹង។

វណ្ណៈ	គ្រូប៉ុន្មាន?

កបៈ	គ្រូរើសអ្នកចេះយើងពីដើមយើងរើសពួកត្រឹមថ្នាក់ទី៨ ទី៩ ចូលធ្វើគ្រូបង្រៀន។ បង្រៀនថ្នាក់យើងពីដើមហៅកុមារដ្ឋាន ថ្នាក់ពហុវចនះដ្ឋាន អទិកដ្ឋាន ខ្ញុំបង្រៀន។

វណ្ណៈ	ប្រហែលប៉ុន្មាននាក់ដែរ បង្រៀន?

កបៈ	គ្រូ៣-៤នាក់។

វណ្ណៈ បង្រៀនរហូតដល់ឆ្នាំណា បានឈប់រៀន ដល់៨៤?

កបៈ ដល់៨៤ហ្នឹងម៉ង ។

វណ្ណៈ ចឹងពី៨៤ មកឆ្នាំ៩០ជាងសមាហរណកម្ម ពូចេញទៅនៅណាទៀត?

កបៈ ក្រោយមកគេឲ្យខ្ញុំមកនៅអូរឬស្សី គេឲ្យខ្ញុំទៅរៀន ថាគេចឹងខ្ញុំនិយាយប្រវត្តិតិចទៅចុះ ក្រោយមកគេជ្រើសរើសអ្នកដែលមានសមាសភាព ។ អ្នកដែលមានកំរិតវប្បធម៌ចាប់ពីទី៧ ចុះ គេមកឲ្យរៀនខាងភស្តុភារ រៀនគ្រប់គ្រងខាងឃ្លាំង ខាងចែកចាយសម្ភារៈអីចឹង ។ បើកអន្តរបើកអីគ្រប់គ្រងសម្ភារៈផ្សេងៗ គឺឲ្យពួកនឹងមករៀន ។ ខ្ញុំក៏មានឈ្មោះមួយដែរ ។ បែបខាងលើយល់ខ្ញុំថា អ្នកពិការ ហើយខ្ញុំមានសមាសភាព គាត់ដាក់ឈ្មោះខ្ញុំមករៀនៗខាងការគ្រប់គ្រងខាងភស្តុភារ រៀនហើយ យើងរៀនបានចប់ហើយ ពាក់កណ្តាលឆ្នាំ៨៥ ខ្ញុំចេញហើយ ខ្ញុំឈប់រៀនហើយ ព្រោះគេថាគេចប់ហើយ គេមានកម្មវិធីមានតេស្តប្រឡង មានវិញ្ញាសារប្រឡងអីចឹងទៅ ខ្ញុំប្រឡងនឹងបានជាប់លេខ៣ដែរ ។ ចឹងខ្ញុំមានភារកិច្ចទៅរៀបចំឃ្លាំងទទួលពួកUNទៀតហើយ ព្រោះខ្ញុំធ្លាប់ធ្វើការជាមួយUNនៅម៉ាឡៃ ។

វណ្ណៈ ចុះប៉ុន្មានពូរៀន ៨៤ ៨៥?

កបៈ ចុង៨៤ ពាក់កណ្តាល៨៤ ។

វណ្ណៈ ពូមករៀននៅណា?

កបៈ រៀននៅកន្លែងការិយាល័យនៅអូរស្វស្តី នៅថ្មដារនេះ ។

វណ្ណៈ ពូនៅនឹងពីឆ្នាំណាដល់ឆ្នាំណា? ក្រោយពីរៀនចប់៨៥?

កបៈ បាទ!

វណ្ណៈ រៀនចប់៨៥ ពូទៅកាន់ឃ្លាំង?

កបៈ បាទ!

វណ្ណៈ កាន់ឃ្លាំងអីគេ?

កបៈ កាន់ឃ្លាំងអន្តរឃ្លាំងអីនឹង សម្រាប់បើកៗចែកឲ្យអន្តភាពដែលនៅខាងក្រោយនឹង កម្លាំងដែលនៅសមរភូមិក្រោយនឹង មីងៗគ្រួសារកងទ័ព អ្នកពិការចឹង ។

វណ្ណៈ ពូមិនបានឡើងច្បាំងទេ?

កបៈ អត់ទេ ខ្ញុំអត់ដែលច្បាំងទេ តាំងពី៧៩មក អត់សោះ បើពិការហើយនៅធ្វើតែការងារក្រោយនឹង ។

វណ្ណៈ កាលនឹងពូ បើពូអត់បានច្បាំងដដែល ប៉ុន្តែពូដឹងថាព័ត៌មានកាលនឹងយួនឡើងវៃជាមួយខ្មែរក្របាមជាមួយអីនឹងមានស្លាប់ច្រើន?

កបៈ	នែក! យើងបានស្តាប់វិទ្យុ បើដឹងជាគេកុហក ក៏កុហកតាមគេ យើងបានព័ត៌មានវិទ្យុកម្ពុជាប្រជាធិបតេយ្យ ឲ្យយើងមានវិទ្យុស្តាប់ទូលាយហើយ ។ ហើយកងទ័ពនៅខាងចលនាតស៊ូខ្មែរក្រហមនៅព្រំដែននឹង គេសុទ្ធតែបើកវិទ្យុឲ្យហើយ វិទ្យុNasonalថ្ងៃ២គ្រាប់នឹងស្រោមក្រហម ។ ចឹងវិទ្យុយើងស្តាប់គ្រប់តែប៉ុស្តិ៍នឹង ។ យើងស្តាប់ភ្នំពេញក៏ស្តាប់ ប៉ុស្តិ៍កម្ពុជាប្រជាធិបតេយ្យក៏ស្តាប់ ឲ្យតែមានម៉ោងស្តាប់យើងស្តាប់ទាំងអស់ ព្រោះគេអត់ប្រកាន់ទេ ។ មេៗមួយចំនួនគេមិនឲ្យស្តាប់វិទ្យុដែរ ប៉ុន្តែមានមេមួយចំនួនដែលគាត់អ្នកចេះដឹង គាត់វិភាគបានល្អ ហើយខ្ញុំក៏រួមចំនែកដែរ ។ បញ្ហាមនុស្សចង់ខ្លួនជាប់ តែចង់ចិត្តមិនជាប់ ចឹងរលកធាតុអាកាស យើងមិនមែនទៅអង្គុយស្តាប់គេក្រោមផ្ទះទេ គេចង់ដាក់អាខ្សែឌឹបដាក់ត្រចៀកស្តាប់ ។ ចឹងមិនបាច់គាបទេ ឲ្យគាត់ស្តាប់ម៉េចស្តាប់ទៅ គេស្តាប់គ្រាន់កែកំសាន្ត គេទទួលព័ត៌មានផ្សេងៗឯខ្លួនគេ ចិត្តគេនៅជាមួយយើង ។ ចឹងបានយើងចង់ខ្លួនបាន តែចង់ចិត្តមិនជាប់ទេ ។ បើគេនៅជាមួយយើង ប៉ុនចិត្តគេមិននៅជាមួយយើងក៏អត់បានប្រយោជន៍ដែរ ។ ចឹងចង់ឲ្យនៅជាមួយយើងទាំងចិត្តទាំងខ្លួន បើកសិទ្ធិឲ្យគេស្តាប់ទៅព័ត៌មាន ពិបាកអីគិតតែស្តាប់វិទ្យុនឹង ។ អ្នកខ្លះគ្រាន់តែស្តាប់រឿងនឹង ប៉ុស្តិ៍ភ្នំពេញច្រើនតែលេងរឿងតេជោមាស លេងរឿងស្អីៗល្ខោនបាសាក់ ។ តែអង្គភាពខ្លះមិនឲ្យស្តាប់ផង តែក្រោយមកយើងប្រជុំចេះនិយាយតៗគ្នា គេថាអង្គភាពនេះ អង្គភាពនោះគេស្តាប់បាន អង្គភាពនោះស្តាប់ទាំងអស់គ្នាបណ្តោយ ។

វណ្ណៈ	ចឹងពូត្រឡប់មកនៅថ្មដានេះ នៅតាំងពី៨៥រហូតដល់បច្ចុប្បន្ន?

កបៈ	វាច្រើនដំណាក់ណាស់ ឆ្នាំ៨៤ខ្ញុំចប់ហើយ ដើមឆ្នាំ៨៥នេះ យួនវាបើកយុទ្ធនាការទ្រង់ទ្រាយធំវៃផ្តាច់កម្លាំងខ្មែរក្រហមនៅព្រំដែន ចឹងវាវៃពួកយើងដាច់នៅអូរស្មួស្តី នៅ៦៣ នៅថ្មដានេះ ពួកយើងមិនធ្លាក់ដីថៃឆ្នាំ៨៥ ខែ៣នឹង យើងធ្លាក់ចូលដីថៃអស់ហើយ ។ តែធ្លាក់ចូលដីថៃ កម្លាំងនៅខាងក្រោយ គ្រួសារកងទ័ព គ្រួសារពលី ជនពិការ និងចាស់ៗ ចុះមកដីថៃអស់ហើយ ។ គេឲ្យមកនៅដីថៃៗ គេផ្តល់កន្លែងឲ្យនៅ គេមានកំណត់កន្លែងតំបន់ឲ្យយើងនៅច្បាស់លាស់នៅចំណុចណាៗ យើងមកនៅដីថៃមក ឆ្នាំ៨៥ ។

វណ្ណៈ	កាលជំនាន់នឹង ដូចថាថៃ-ខ្មែរយើង មានទំនាក់ទំនងល្អជាមួយគ្នាអានឹងដោយសារមូលហេតុអីដែរ បើតាមពូយល់?

កបៈ	តាមខ្ញុំយល់អានេះ អាសត្វថៃ យកខ្មែរយើងធ្វើរបងៗ យកខ្មែរពន្លត់ភ្លើងយ៉ាងម៉េចភ្លើងឆេះដល់ស្រយាបផ្ទះហើយ ចឹងយើងមិនបាច់ហត់ពន្លត់ ។ ចោរមកដល់ហើយ មិនបាច់ពិបាកការពារ គ្រាន់ផ្តល់កន្លែងឲ្យគេនៅ ដូចពួកខ្ញុំខាងខ្មែរក្រហម យួនដេញធ្លាក់នឹង គេឲ្យនៅជាយដែនគេនឹង ដូចការពារឲ្យគេ ។

វណ្ណៈ៖ ប៉ុនចលនាយួនខ្លាំងបំផុតឆ្នាំ៨៥ ?

កបៈ បាទ!

វណ្ណៈ៖ ដល់៨៧ ៨៨ យួនដកចេញទៅអស់ ពេលនឹង?

កបៈ យួនខ្លាំងដែលខ្ញុំដឹង ។ យួនខ្លាំងបានតែ២ឆ្នាំ ៨៥ ៨៦ ។ ៨៧ ចុះខ្សោយវិញហើយ ។ ៨៧ដែលខ្ញុំនិយាយខាងដើម និយាយមុនលោកឯងសម្ភាសន៍ ៨៧នឹងហើយដែលចលនាខ្មែរក្រហមវ៉ៃបើកព្រំដែនវិញ វ៉ៃដាច់ក្បាលឡាន ភ្នំផ្កាយព្រឹក្សនេះ យើងបើកច្រករហូតដល់រំដោះទីតាំងកងពលនៅតាគោក អានឹងទីតាំងកងពល ។ រំដោះទីតាំងកងពលតាគោកអីបានទឹកស្រុក យើងមិនយកកម្លាំងឡើងមកដីយើងវិញ ដោយសារអី ដោយសារកម្លាំងទាហានខ្មែរគាត់ចុះមកជួបជាមួយខ្មែរក្រហម ។ យើងបានកម្លាំងច្រើន យើងបើកយុទ្ធនាការបុកបើកព្រំដែន បើកបានមែន ។

វណ្ណៈ៖ ចឹងដល់ពេលវៀតណាមដកចេញទៅប្រទេសកម្ពុជាឆ្នាំ៨៨ ៨៩នេះ តើមានខាងដូចចិនអីផ្តល់ជំនួយឲ្យទៀត ឬក៏ឈប់ហើយចិន ឬខាងខ្មែរក្រហមដោះស្រាយខ្លួនឯង?

កបៈ តាមពិតទៅរបស់នោះនៅប្រើតែកងទ័ពទេ របស់សល់ពីជំនួយ ឯអ្នកកម្លាំងនៅខាងក្រោយគឺអ្នកដឹកនាំទៅទិញដោះស្រាយអន្តភាព ដោះស្រាយកម្លាំងទាំងអស់ដែលនៅក្នុងចលនាតស៊ូទាំងអង្គរ ស្បែកក្រែ ខោអាវសំលៀកបំពាក់ យើងទិញឡើងពីថៃមកទាំងអស់ ជាសារុង ជាក្រមា ប៊ីចេង ប្រេងឆា សណ្តែក ទឹកដោះគោ គឺទិញដឹកមកពីថៃឡើងមកទាំងអស់ ។

វណ្ណៈ៖ ពេលសង្គ្រាមខ្មែរនិងខ្មែរទល់គ្នា ខ្មែរខាងរដ្ឋកម្ពុជាខាងសម្តេចហ៊ុន សែន ហើយនឹងខាងខ្មែរយើងខាងតស៊ូនឹង វ៉ៃគ្នានឹង អានឹងលែងមានទ្រង់ទ្រាយធំហើយ វ៉ៃតាមធម្មតាដូចមានរបេះរបោះ មិនសូវជាវ៉ៃសម្លាប់ស៊ីសាច់ហូតឈាមគ្នា?

កបៈ បាទ! អានឹងលែងស៊ីសាច់ហូតឈាមហើយ វ៉ៃការពាររៀងខ្លួន ខាងក្នុងការពារយើងមិនឲ្យចូល ឯយើងនេះក៏ការពារខាងក្នុងមិនឲ្យចូលដែរ ។ ចឹងខ្ញុំឃើញស្ថានភាពមួយ សភាពការណ៍១ឆ្នាំ៩៣នឹង ខាងខ្មែរក្រហម ខាងចលនាតស៊ូយើងមិនបើកទូលាយឲ្យបងប្អូននៅស្រុកនោះចូលមកលេងបងប្អូននៅព្រំដែន ។ ហើយបងប្អូនខ្ញុំក៏មានមកដែរ មកបានជួបដំណឹងបានយកដំណឹងថានៅរស់ ថាបងប្អូននៅស្រុកវិញ ។

វណ្ណៈ៖ ៩៣អ៊ុនគាត់ចូល?

កបៈ ហ្នឹងហើយ ខ្ញុំចាំច្បាស់ណាស់ ។

វណ្ណៈ៖ ប៉ុន្តែម៉ាឡៃ អ៊ុនគាត់ អត់ចូលបានទេ១ តាមជំនៀរព្រំដែនម៉ាចំនួន?

កបៈ បាទ!

វណ្ណៈ អត់បានបោះឆ្នោតទេ ដោយសារថា យើងអត់ត្រូវជាមួយខាងក្នុង ហើយខាងកាលមុនដំបូង ការចចារនៅប៉ារីស ចចារនៅចាកាតាអីយើងថាត្រូវគ្នាដំហរបោះឆ្នោតទាំងអស់គ្នា ប៉ុន្តែក្រោយមកខាងខ្មែរក្រហមបានដកខ្លួនចេញ មិនចូលរួមបោះឆ្នោត ។ ចឹងហើយបានមានបញ្ហាមួយចំនួនទៀត យើងត្រូវនៅបន្តសង្គ្រាមតូចៗ?

កបៈ បាទ! អានឹងចឹងហើយ ។ កាលដែលខ្មែរក្រហមអត់ចូលរួមបោះឆ្នោត ខ្មែរក្រហមបង្កើតកម្លាំងចលនាតស៊ូទប់ជាមួយរដ្ឋាភិបាលម្ដងទៀត អានឹងអស់យូនហើយ យើងទប់ជាមួយរដ្ឋាភិបាល ។ ឆ្នាំ៩៨ រដ្ឋាភិបាលវ៉ៃបុកនៅប៉ៃលិនៗចូលម៉ាឆុល ពួកប៉ៃលិនវ៉ៃវាបុកម៉ាឆុលវិញ ចេញទៅវិញអស់ទៀត ។

វណ្ណៈ ចុះដល់ពេលឆ្នាំណាពិតប្រាកដពូមកនៅនេះ?

កបៈ ខ្ញុំឆ្នាំ៩៩មកនៅនេះ ។

វណ្ណៈ ចឹងពី៨៥ ដល់៩៨ពូនៅណា?

កបៈ ខ្ញុំនៅសំឡូត ។

វណ្ណៈ អូ!នៅសំឡូត?

កបៈ បាទ! នៅសំឡូត ។

វណ្ណៈ នៅសំឡូត បានបោះឆ្នោត៩៣?

កបៈ អត់ទេ ។

វណ្ណៈ នៅសំឡូតពីណាគ្រប់គ្រង ផ្នែកសំឡូត?

កបៈ សំឡូត ការគេហៅច្រកសំឡូតនៅខាងជើង ស៊ូ សាម៉េត(តាមពិតស៊ូ ម៉េត) អូរខ្វាឃុំ ឯងម៉ាដួរយើងអូរនោងតាគោកអានឹង មាស មុត ។

វណ្ណៈ នៅសំឡូត មាស មុត?

កបៈ នៅសំឡូត មាន ស៊ូ សាម៉េត សំឡូតវាច្រក មានមុខសញ្ញាចែកតំបន់គ្នាគ្រប់គ្រងក្នុងស្រុកភូមិសាស្ត្រស្រុកតែមួយទេ ។ ប៉ុនផ្នែកខាងជើង ស៊ូ សាម៉េត, ផ្នែកខាងត្បូង មាស មុត ។

វណ្ណៈ ខាងជើង ខាងត្បូងស៊ូ សាម៉េត?

កបៈ ខាងជើង ស៊ូ សាម៉េត ខាងត្បូង មាស មុត ។

វណ្ណៈ គាត់សព្វថ្ងៃនៅរស់?

កបៈ នៅរស់ ។

វណ្ណៈ ប៉ុន្តែពូនៅជាមួយ ដូចថាខាងក្រោមនៅជាមួយប្រជាជនណាអីទេ ដោយសារពូចំការ?

កបៈ បាទ! នៅខាងក្រោយទេ នៅសំឡូត ខ្ញុំធ្វើគ្រូបង្រៀនដែរ ។

វណ្ណៈ គ្រូបង្រៀននៅសំឡូតទៀត?

កបៈ បាទ!

វណ្ណៈ ពូជួយជាតិបានច្រើន?

កបៈ បាទ!

វណ្ណៈ ចឹងឥឡូវ សព្វថ្ងៃពូគ្រូបង្រៀនដែរ?

កបៈ នាយកសាលា បង្រៀនផង នាយកផង។

វណ្ណៈ នាយកសាលាណា?

កបៈ នាយកសាលាបឋមសិក្សាដីក្រហម។ សាលាទើបនឹងធ្វើ ខ្ញុំសុំលោកតានៅ New Zealand លោកឲ្យសុំផ្ទាល់មុនមកផ្ទះលុតជង្គង់ថ្វាយបង្គំសុំគាត់។

វណ្ណៈ សាលាណា?

កបៈ ព្រះអង្គនៅ New Zealand មុនៗដឹងលោកតានិមន្តមកពីបរទេសលោកមានសុំលុតជង្គង់ ខ្ញុំប្រគេនចង្ហាន់លោក និមន្តមកពាអង្គ លុតជង្គង់ថ្វាយបង្គំឲ្យបណ្ដោយ សុំខ្ទួនឯង ព្រោះខ្វះអគារ។

វណ្ណៈ យើងមិនមែនសុំយកខ្ទួនឯងណា យើងសុំឲ្យកូនចៅរៀនសូត្រ?

កបៈ បាទ! ឲ្យសិស្សឲ្យកុមារបានរៀបសូត្រ ព្រោះខ្វះអគាររៀន។

វណ្ណៈ មើល៩៨ សមាហរណកម្មហើយ?

កបៈ ៩៧។

វណ្ណៈ ៩៧?

កបៈ បាទ! យើងសមាហរណកម្មខែ១០ ៩៦។ ៩៧យើងត្រូវវ៉ូវក្នាមែនទែនហើយណា ដល់ខែ៧ ខែ៨ ៩៧ យើងមានថ្ងៃ៥ ថ្ងៃ៦ គេមិនធ្វើរដ្ឋប្រហារនៅភ្នំពេញ តែនៅព្រំដែននេះគេមានចលនាមួយទៀត។ ខ្ញុំនៅសល់ពងក្ដពា គួចខោទទេរដោយសារចលនាចុងក្រោយនេះ។

វណ្ណៈ ចលនាម៉េច?

កបៈ មាស មុត និង អៀង ថាន់ គេមិនគៀរពួកខ្ញុំទៅជំរំទៅដីថៃម៉ាសារទៀត គេបង្កើតចលនាតស៊ូជាមួយរដ្ឋាភិបាលម្ដងទៀតប្រឆាំងជាមួយសម្ដេចនាយក ហើយខ្ញុំគិតថាគ្មានប្រយោជន៍ទេ។ ខ្ញុំប្រឆាំងគេកាលនឹង ប្រាប់ទៅក្នុងបទសម្ភាសន៍ខ្ញុំនិយាយជា....(ស្ដាប់មិនបាន) គេចាប់ខ្ញុំយកមកនេះ សួរប្រពន្ធខ្ញុំៗនៅកូនចៅយំហើមភ្នែក រឿងខ្ញុំប្រឆាំងគេ។ ខ្ញុំប្រឆាំងគេខ្ញុំប្រឆាំងខ្ញុំលើកថា ពីមុនយើងនៅជាផ្ទាំង ពីមុនការតស៊ូ នៅជាផ្ទាំងបើនិយាយពីសាច់នៅជាសាច់ដុំ ឥឡូវនេះមិនត្រឹមតែសាច់រាយទេ សាច់អន់ទៀត បើប្រៀបធៀបដូងនៅម៉ាចំរៀក

បើយើងខ្លាំងទៀត គឺដាច់ខ្យល់ហើយ គេចោទខ្ញុំថាចិន ។

វណ្ណៈ: តែពូនិយាយត្រឹមត្រូវ វិភាគត្រឹមត្រូវហើយ បើគេកម្ទាំងពេញអស់ហើយនឹង?

កបៈ: ពីមុនកម្ទាំងតស៊ូវានៅជាដុំកំភួន បើសាច់វានៅជាសាច់ដុំទាំងអស់ ដល់យើងសុវណ្ណសាម សាច់វាបែកអស់ហើយ ។

វណ្ណៈ: បែកអស់ ទាំងប៉ាវ៉ាទាំងអីចូលខាងនោះអស់?

កបៈ: បាទ! ចិនយើងទៅធ្វើអីកើតមានតែម្នាក់ឯង អត់មានជំនួយយកទៅធ្វើអី ធ្វើអីចេញដំណាក់កាលនេះធ្វើសង្គ្រាមឈ្លបវាហួសហើយ ខ្ញុំប្រាប់ចិន ។

វណ្ណៈ: ប្រឆាំងជាមួយតាមុត?

កបៈ: ប្រឆាំងជាមួយតាមុត បើយើងថានឹងគេចាប់ខ្ញុំយកមកឃុំនៅអូរត្រែងនេះ បានមានមិត្តភ័ក្តខ្ញុំ សាលននឹង ញ៉ៅរ គាត់វរៈសេនាធំនៅវាលចំបាំង គាត់ធានាដោះយកមកវិញ មិត្តភ័ក្តចាស់ ។ ចុះទៅធ្វើបាបអីអ្នកពិការ ទៅធ្វើអីកើតមនុស្សតែមួយ មនុស្សតែម្នាក់ឯងនឹងមនុស្សបានសម្តីនឹង ។

វណ្ណៈ: ចាប់យកទៅដាក់ឃុំប៉ុន្មានថ្ងៃ លែង?

កបៈ: ប្រហែលកន្លះខែ គេមកចាប់ដល់ផ្ទាល់ ហើយ ស្វាយ ម៉េត អ្នកចាប់ប្រធានការិយាល័យផែនការស្រុកវាលវែង...(ស្តាប់មិនបាន) មនុស្សជំនាន់នឹង ពួកដៃស្តាំ អៀង ដាន, មាស មុត នឹងហើយ ។ ខ្ញុំបានមានឱកាស ខ្ញុំបើកកកាយឲ្យអស់ ខ្ញុំឱនចិត្ត បានតាលន តាញ៉ៅរនឹងតើ គេធានានោះ តាមពិតធ្វើបាបគាត់ធ្វើអី តានឹងបានតែមាត់ទេ ។ ប៉ុនតាលន នឹងអតីតជា.....(ស្តាប់មិនបាន) គាត់មកនៅនឹង ។ ប៉ុនអត់ពីតា គាត់មានតួនាទីជាវរសេនាធំចិនគេប្រជុំថ្នាក់លើជាមួយ មាស មុត គាត់លើកបញ្ហា ដើម្បីសម្រាលឲ្យខ្ញុំត្រឡប់មកផ្ទះវិញ ។ ខ្ញុំបានមកវិញមក ដោយសារគាត់ជួយ ។

វណ្ណៈ: ចុះអាគេថ្ងៃ៥-៦ រឹកវរនៅនោះហើយ នៅខាងនេះមានបញ្ហាទៀត?

កបៈ: មានបញ្ហា នៅបើប្អូនឯងមិនជឿ សួរយាយវឿន សួរសែម សួរតានី ឲ្យតែអ្នកតស៊ូចាស់គឺគេកៀរទៅនឹងទាំងអស់ ។

វណ្ណៈ: កាលនឹងថ្ងៃ៥-៦ខែប៉ុន្មាន ពូចាំខែ?

កបៈ: ខ្ញុំដូចភ្លេចហើយខែ ។

វណ្ណៈ: ឆ្នាំ៩០ប៉ុន្មាន?

កបៈ: ឆ្នាំ៩៧ ខ្ញុំចាំឆ្នាំច្បាស់ណាស់ ។

វណ្ណៈ: ៩៧នឹងដែរ?

កបៈ បាទ! ៩៧ ។

វណ្ណៈ ៩៧ ៩៨?

កបៈ ៩៧ ។

វណ្ណៈ មុនបោះឆ្នោត?

កបៈ មុនបោះឆ្នោត គេកៀរពួកខ្ញុំ គេធ្វើរដ្ឋប្រហារនៅភ្នំពេញ ពួកនៅសំឡូតនេះគេបង្កើតចលនាមួយទៀត គេកៀរកម្លាំង ខ្ញុំនិយាយប្រាប់ត្រង់ខ្ញុំរៀបរទេះគោ រៀបសម្ភារៈហើយអស់ហើយ ខ្ញុំមិនទៅលិចទេ។ ដឹងថាទៅលិចសល់តែគូថខោហើយ ចឹងយើងគិតជាមួយ តាញ៉ូរ ហើយគេមិនដែលចោលខ្ញុំពេលដែលមានសភាពការណ៍ គេតែងតែហៅខ្ញុំទៅចូលរួមពិគ្រោះយោបល់ ព្រោះគេដឹងថាខ្ញុំអតីតមេចាស់មុនគេ។ គេឲ្យទៅសួរឆ្លើយយោបល់ ខ្ញុំថាឥឡូវទៅលិច សល់តែគូថខោទេមកវិញ បើទៅកើតយើងរស់។ យើងសល់គោ យើងសល់ក្របី យើងសល់ដីធ្លីយើង គិតដំណើរការណ៍ពួកខ្ញុំគិតឯកភាពគ្នាថា ឥឡូវទៅកោះក្រឡ ដីកោះក្រឡណែនាំមិនខ្វះ ដីស្រែនឹង យើងទៅនៅនឹង។ ចុះទាហានរដ្ឋាភិបាលមកមុខ យើងនៅក្រោយយើងធ្វើស្រែទៅ មិននៅរស់ យើងបានដីស្រែ យើងមានស្រូវហូប មានបាយហូប កូនចៅយើងមិនរស់។ ហើយបើទៅលិចសល់តែគូថខោទេទៅវិញ ចឹងយើងរៀបរទេះគោរៀបអីតាញ៉ូរឲ្យរៀបចំកម្លាំងចុះស៊ើបការណ៍ៗយ៉ាងម៉េចៗដែលយើងត្រូវចេញ ទៅដល់កងទ័ពរាយការណ៍វិញ គេដាក់អាចមន៍គោ អាចមន៍ក្របីនៅពេញទឹកពេញដីអស់ ខ្លានៅពេញព្រៃកូនខ្លា កងទ័ពតានឹង។ ចឹងយើងចេញអត់រួច គេកំណត់ឲ្យខ្ញុំចេញម៉ោង៧ ខ្ញុំអត់ចេញចុងក្រោយបំផុត ដែលគេយកកាណុងមកកៀរខ្នង ដែលខ្ញុំមិនព្រមទៅតាមគេ។ គេយកកាណុងមកកៀរខ្នង ខ្ញុំស្រក់ទឹកភ្នែកថាខឹងដោយសារអី ពីមុនមនុស្សវាស៊ីឆៅដែរ ស៊ីដាច់រឿងសង្គ្រាម មិនចេះចាញ់អ្នកណាម៉ាពេល ស្រក់ទឹកភ្នែកដោយសារធ្វើអីគេមិនកើតដោយសារពួកអាតូចៗប៉ុននេះឲ្យរយ៉ុង បើវៃវាឯាប់ពួកអានឹង ចឹងសុខចិត្តចាញ់គេទៅ កូនក្មួយខ្ញុំនៅអូរដើមចេក កូនលោកគ្រូពៅ។ កូនក្មួយទាំងអស់ម៉ាផ្ទះ ម៉ាជួរសុទ្ធតែកូនក្មួយរបស់ខ្ញុំទាំងអស់បងប្អូនទាំងអស់ គេចាំមើលតែខ្ញុំ ហើយពួកនឹងគេទាញអាវុធអស់ហើយ ចាំទៅមើលខ្ញុំបញ្ជាឲ្យផ្ទុះ ខ្ញុំគិត បើផ្ទុះស្លាប់ទាំងអស់គ្នា។ ចឹងសុខចិត្តអស់ទ្រព្យសម្បត្តិឲ្យតែក្មេងជីវិតមនុស្សនៅរស់ ខ្ញុំគិតចឹង។ ខ្ញុំថាតស់ពួកយើង ទៅ។

វណ្ណៈ ដល់ចឹងកៀរពូទៅដល់ណាទៀត?

កបៈ ទៅដល់គេហៅនៅ ទៅដល់កន្លែងជំរំខ្មែរក្រហមចាស់ គេហៅអូរល្ហុង។

វណ្ណៈ នៅត្រឹមហ្នឹង?

កបៈ បាទ! នៅត្រឹមហ្នឹង ។

វណ្ណៈ ប៉ុន្តែរយៈពេលខ្លីដែរ ម៉ាព្រិចភ្នែកដែល?

កបៈ ទេ! ប្រហែលជា២ឆ្នាំដែរ ។

វណ្ណៈ ២ឆ្នាំដែរ យូរ?

កបៈ បាទ! យើងចុះទៅជំរំខែ៨ ឆ្នាំ៩៧ យើងឡើងមកវិញខែ២ ឆ្នាំ៩៩ ម៉ាឆ្នាំ៧-៨ខែ ។

វណ្ណៈ កងកម្លាំងមាស មុត?

កបៈ បាទ! មាស មុត និង អៀង ផាត វាកៀរពួកខ្ញុំទៅ ។ មិនថាពួកខ្ញុំទាំងអស់ អ្នកដែលនៅសំឡូតពួកសមាហរណកម្ម កៀរទៅនឹងវិញទាំងអស់ ។

វណ្ណៈ ទៅនៅជាប់ព្រំដែនថៃវិញ?

កបៈ បាទ! ទៅនៅដីថៃបណ្ដោយ នៅអូរល្ហុង ហើយបើថៃគេហៅខោរូ ។

វណ្ណៈ អូរល្ហុង?

កបៈ បាទ! ខ្មែរយើងហៅអូរល្ហុង ប៉ុនថៃវាហៅរូ ភ្នំរូ នៅនឹង ។

វណ្ណៈ ពី៩៧ ដល់?

កបៈ ខែ២ ៩៩ យើងមាតុភូមិនិវត្តន៍ត្រឡប់មកវិញ ដោយសារអៀង ផាតនឹង គាត់អស់មានលទ្ធភាពតស៊ូជាមួយរដ្ឋាភិបាល គាត់ចចារជាមួយរដ្ឋាភិបាល សុំចុះចូលជាលើកទី២ ។ សមាហរណកម្មលើកទី២ហើយ ឆ្នាំ៩៩ ។

វណ្ណៈ អៀង ផាត សព្វថ្ងៃគាត់នៅ?

កបៈ នៅតើ ។

វណ្ណៈ ឥឡូវគាត់នៅធំដដែល?

កបៈ នៅធំដដែល ពួកគេនិយាយថានៅភូមិភាគនៅអី ។

វណ្ណៈ ចឹងចូលជាមួយរដ្ឋាភិបាលលើកទី២ បាននៅសុខរាល់ថ្ងៃ?

កបៈ បាទ! បាននៅសុខដល់រាល់ថ្ងៃ ។

វណ្ណៈ មកដល់នឹង៩៩ ព្រៃឈើយើងចាប់អស់ខ្ជះបណ្ដើរៗ ឬមិនទាន់?

កបៈ ដូចនៅទេ ម៉ុនឹងសុទ្ធព្រៃទាំងអស់កាលខ្ញុំមក ហើយអត់ទាន់មានផ្លូវទេ ៩៩ យើងដើរកាត់ព្រៃ បើផ្លូវយើងជិះឡាន យើងបើកបរចេញចូលរាល់ថ្ងៃនេះ ពីដើមពីអតីតផ្លូវ៥៦ ។ ចឹងសុទ្ធតែមីន យើងអត់ហ៊ានដើរ យើងដើរផ្លូវកាត់ៗដែលយើងធ្លាប់ដើរពីមុនមក ដើរកាត់ក្នុងព្រៃ ។

វណ្ណៈ៖ ចុះពូ ឧបមាថា បើពូគិតមើលទៅខាងសម័យតស៊ូ ហើយមកដល់សម័យឥឡូវនេះ ពូគិតថា មួយណាមានរស់នៅស្រួលជាង យ៉ាងម៉េចដែរ?

កប៖ វា ម្យ៉ាងម្នាក់ សម័យតស៊ូយើងមិនមានសិទ្ធិបញ្ចេញយោបល់អីទូលំទូលាយអីមែន ប៉ុន្តែការរស់នៅគ្មានអ្នកកៀបសង្កត់ ។ តែឥឡូវនេះសព្វថ្ងៃ មានប្រព័ន្ធសព្វផ្សាយទូលំទូលាយ ប៉ុន្តែនៅតែមានការកៀបសង្កត់ ។ ចឹងស្ថានភាពទាំងពីរយើងប្រៀបធៀបទៅ វាសព្វថ្ងៃយើងរស់នៅល្អជាង ។

វណ្ណៈ៖ ល្អជាង?

កប៖ បាទ! ល្អ ។

វណ្ណៈ៖ ប៉ុន្តែមិនទាន់ទូលំទូលាយប៉ុន្មាន?

កប៖ មិនទាន់ទូលំទូលាយប៉ុន្មានទេ ប៉ុនយើងអាចរស់នៅបានក្នុងការមានសិទ្ធិសេរីភាពក្នុងដើរហើរ ចុះឡើងទៅលេងស្រុកភូមិ និយាយរួមសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ យើងមានសិទ្ធិពេញទំហឹង ។

វណ្ណៈ៖ ចឹងខ្ញុំចង់ឲ្យពូវិភាគមើលថា តើរវាងខ្មែរនិងខ្មែរយើង ប្រហែលជាលែងលាបពណ៌វៃគ្នាខ្មែរនិងខ្មែរតទៅមុខទៀត ឬក៏នៅមានទៀត បើសិនជាពូធ្វើការវិភាគមើល ការគិតមើល?

កប៖ តាមខ្ញុំវិភាគមើល ហើយនិងមើលស្ថានភាព មិនមានទៀត ។

វណ្ណៈ៖ មិនមានទៀតទេ?

កប៖ ព្រោះខ្មែរយើង ក្រែងក្មេងជំនាន់ក្រោយ ប៉ុនក្មេងជំនាន់ដល់វាងងឹតប្រទេសមានការអភិវឌ្ឍជឿនលឿន មនុស្សវាមិនចង់ធ្វើទេសង្គ្រាមទេនោះ ត្រូវការសប្បាយ ខ្លាចតែពួកកញ្ចាស់ៗដូចពួកខ្ញុំតើដែលបង្កើតវិញនោះ ។ ប៉ុនពួកយើងកញ្ចាស់ៗនេះមិនចង់ទេ ស្អប់ណាស់សង្គ្រាម ស្អប់បំផុតសង្គ្រាមនឹង ។ ទោះបីអត់ឃ្លាន មានហូប ឲ្យតែប្រទេសសុខសាន្តត្រាណ កូនចៅរស់នៅបានស្រួល កុំព្រួគ្រាប់អាវុធ កុំឲ្យព្រួស្នូលគ្រាប់កាំភ្លើង អាវុធជាតិផ្ទុះអីផ្សេងៗ ឲ្យវាស្អប់ដូចសព្វថ្ងៃ យើងទោះបីជាយើងខ្វះខាតម៉េច ក្នុងជីវភាពដែលយើងរកបាន ។ ធ្វើម៉េចបើយើងរកមិនបានវាចឹង បើយើងខំយើងបាន បើយើងមិនខំអត់ទៅ ប្រទេសលទ្ធិប្រជាធិបតេយ្យផ្សារសេរី អ្នកណារកបានមាន អ្នកណារកមិនបានអត់ទៅ តាមតំរិះរៀងខ្លួន ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរតិចទៀតថា ដូចថាមកដល់ស្រុកវាលវែងនេះ យើងបង្កើតជាភូមិឃុំ ចងក្រងជាភូមិឃុំស្រុកឆ្នាំណា ដែលយើងចាប់ផ្តើមបង្កើតចេញជាភូមិឃុំស្រុក?

កប៖ បើតាមខ្ញុំដឹង ស្រុកនេះវាបង្កើតពេលសមាហរណកម្មនឹងតែម៉ង អនុសាសន៍សម្តេចគាត់ផ្តល់ គាត់ខ្លាចបងប្អូនទាំងអស់ត្រឡប់ទៅស្រុកវិញទេ ។ ហើយបើបងប្អូនមិនទៅស្រុក គាត់អរ

ណាស់ ចឹងបងប្អូននៅកន្លែងណា រស់នៅកន្លែងនឹងចុះ ហើយបងប្អូនមានសិទ្ធិកាន់កាប់ដីធ្លីធ្វើអាជីវកម្មដាំដុះចិញ្ចឹមជីវិត ។ ហើយសម្តេចចុះមកសួរសុខទុក្ខប្រជាពលរដ្ឋ និងកងទ័ពនៅស្រុកសំឡូត កាលនឹងខ្ញុំនៅអូរដើរចេកនៅឡើយទេ ខ្ញុំបានទៅទទួលគាត់ទៀត ហើយខ្ញុំនៅកន្លែងឃុំកំពង់ល្ពៅ គេដាក់ចំមុខវេទិការម៉ង ហើយខ្ញុំប្រធានអប់រំនៅកំពង់ល្ពៅ គេហៅប្រធានអប់រំឃុំ ខ្ញុំរៀបចំសិស្សអង្គុយនៅមុខវេទិការនឹង ។ ចឹងខ្ញុំស្តាប់បានច្បាស់ណាស់អនុសាសន៍គាត់ ។ ហើយអ្នកណាធ្លាប់ធ្វើអីធ្វើទៅ ធ្លាប់អ្នកធ្វើទាហានៗ អ្នកធ្វើពេទ្យៗ អ្នកធ្វើគ្រូៗ អ្នកធ្វើប៉ូលីសៗគាត់ថាចឹង អ្នកណាធ្វើអីធ្វើនឹង គួនាទីអត់ដកទេ ដីធ្លីក៏មិនដក បងប្អូនធ្វើចុះ ។ គាត់ខ្វាចតែបងប្អូនទៅស្រុកជាបន្ទុកធ្ងន់ដល់រដ្ឋាភិបាល ។ ចឹងបើបងប្អូននៅនេះនៅកន្លែងណានៅកន្លែងនឹង គាត់អរ គាត់ផ្តល់សិទ្ធិឲ្យកាន់កាប់ដី ។

វណ្ណៈ ចឹងសព្វថ្ងៃនេះ សាលានៅស្រុកយើង ស្រុកវាលវែងនឹង មានសាលាបឋមសិក្សាប៉ុន្មាន វិទ្យាល័យប៉ុន្មាន ពូដឹងទេ?

កបៈ សាលាបឋមមាន២០ ។

វណ្ណៈ ២០?

កបៈ បាទ!

វណ្ណៈ ចុះវិទ្យាល័យប៉ុន្មាន?

កបៈ វិទ្យាល័យ១ ។

វណ្ណៈ វិទ្យាល័យតែមួយ?

កបៈ បាទ! វិទ្យាល័យប្រមោយ ។

វណ្ណៈ ខ្ញុំចង់សួរម៉ាសំនួរទៀត ទាក់ទងតុលាការពូបានស្តាប់ខ្លះៗមកទេ តុលាការទោស?

កបៈ ស្តាប់ដែរតើ ។

វណ្ណៈ ពូយល់យ៉ាងម៉េចដែលចំពោះតុលាការ?

កបៈ អានឹងរឿងរបស់តុលាការ អានឹងត្រង់ណាធ្វើខុស ទទួលទៅ ខ្ញុំគិតតែចឹង ព្រោះសម័យនឹងខ្ញុំក៏ជាអ្នករងគ្រោះក្នុងរបបនឹងដែរ ។ ចឹងគាត់ជាមេដឹកនាំក្នុងស្អី គេហៅលេខ០០២ស្អី ។

វណ្ណៈ ០០២?

កបៈ ០០២គេហៅស្អី ។

វណ្ណៈ ០០១ ករណីកាំងហ្គេចអ៊ាវហៅឌុច, ០០២មានលោកតាខៀវ សំផន, លោកតាអៀង សារី, នួន ជា ។

កបៈ អៀង សារី, នួន ជា, ហើយអៀង ធីរិទ្ធ ។ តែគេហៅស្អី០០៣នេះគេហៅ មកដល់ មាស

មុតអីទៀត ។

វណ្ណៈ៖ អានឹង សេង ធារី គាត់ទម្លាយឈ្មោះទេ ។ តាមពិតទៅ ០០៣, ០០៤នេះ រដ្ឋាភិបាលមិនឲ្យមានទេ ហើយបើសិនជា០០៣, ០០៤កើតឡើងវាអាចមិនតាមាស មុតមួយ វាអាចមានមនុស្សច្រើនទៀត ហើយក្នុងជួររដ្ឋាភិបាលក៏មានខ្លះទៀតដែរ ។

កបៈ ខ្ញុំស្រឡាញ់ចេះ ខ្ញុំស្រឡាញ់ហើយគាំទ្រ គំនិតរបស់សម្តេចនាយក ។ គាត់ធ្វើនេះត្រូវ ខ្ញុំគាំទ្រ បើខ្ញុំនិយាយាចូលក្នុងបទសម្ភាសន៍ គាំទ្រខាងគោលនយោបាយរបស់គាត់ផ្សះផ្សាជាតិ បើឲ្យពួកបរទេសមកហែកហួរ ឲ្យខ្មែរឈ្លោះគ្នាទៀត ។ ចឹងបញ្ចប់ត្រឹមករណី០០២នឹង បានហើយ មិនបាច់ឲ្យមាន០៣, ០៤ ទៀតទេ បញ្ចប់ទៅ ។ សេង ធារី នឹងក៏សំបើង មេខ្ញុំស្អប់ដែរតើ ។ មិនមែនថាខ្ញុំគាំទ្របេះបុះ ប៉ុន្តែ មាស មុត, ស៊ូ សាម៉េតនឹង ក៏គាត់នៅក្រោមបញ្ជាគេដែរ ។ គាត់មិនមែនកំពូលណា ថ្នាក់កំពូលតាៗ៣-៤នាក់នឹង អានឹងកំពូលហើយ ។

វណ្ណៈ៖ ចឹងពូគិតថាបញ្ចប់ត្រឹម០០២ តើដូចថាប្រជាជនអាចទទួលបានយុត្តិធម៌ខ្លះៗដែរ?

កបៈ បាទៗ ។

វណ្ណៈ៖ ចឹងយើងនឹងចាំមើលការកាត់ទោសប្រហែលជាក្នុងឆ្នាំនេះ មិនដឹងខែប៉ុន្មាន បើឆ្នាំនឹង០០២ចាប់ផ្តើមដំណើរការហើយ ។ ប្រហែលជា៣-៤ខែទៀតទេដឹង យើងចាំស្តាប់ទាំងអស់គ្នា ហើយចង់ដឹងថារឿងរ៉ាវដែលគាត់គ្រប់គ្រងនឹង បើសិនជាគាត់ហ៊ាននិយាយលាតត្រដាងការពិតមក យ៉ាងម៉េចៗអានឹងក៏វាល្អដែរ ។ ហើយបើគាត់មិននិយាយអានឹងរឿងរបស់គាត់ផ្សេងទៀត ជាសិទ្ធិរបស់គាត់ ។

កបៈ បាទៗ ។

វណ្ណៈ៖ ចឹងពូមានអីចង់បន្ថែមទៀត ដែលខ្ញុំមិនបានសួរពូ?

កបៈ ខ្ញុំមិនមានអីបន្ថែមទេ ប៉ុន្តែបើក្នុងបទសម្ភាសន៍នេះ បើសិនជាយកទៅចុះកាសែត ចុះពត៌មានសូមបិទ កុំអីកុំឲ្យបង្ហើបឈ្មោះ ប៉ុនយកសម្តីទៅ....(ស្តាប់មិនបាន) ។ ដើម្បីអី ដើម្បីការពារសុវត្ថិភាព ដែលយើងគិតមិនដល់ សំណូមពរតែប៉ុននឹងទេ ។

វណ្ណៈ៖ បាទៗ ចឹងខ្ញុំអរគុណពូច្រើន ។

កបៈ បាទៗ ។

«ចប់»